STREAM

# របាយការណ៍ស្ដីពី

# ការសិក្សាពីនិរន្តរភាពការចិញ្ចឹមជីវិតរបស់

# ប្រជានេសាទ និង កសិករ

# នៅភូមិ

# កោះឫស្សី ឃុំប្រឡាយមាស ស្រុកកំពង់លែង

# ខេត្តកំពង់ឆ្នាំង

ឧបត្ថម្ភដោយ

**គំរោងគាំទ្រដល់ការគ្រប់គ្រងធនធានវារីជាតិក្នុងតំបន់**

**សហការជាមួយ**

**ការិយាល័យអភិវឌ្ឍន៍សហគមន៍នេសាទនៃនាយកដ្ឋានជលផល និង**

**កម្មវិធី ស្កេល**

**សីហា ២០០២**


Bhutan
Bangladesh
Myanmar (Burma)
Laos
Vietnam
Paracel Islands
Philippines
Thailand
Cambodia
Spratly Islands
Macau
Brunei
Malaysia


Otdar Mean Chey
Banteay Mean Che
Seam Reap
Preah Vihea
Steung Traeng
Rotanak Kiri
Battambong
Great Lake
Pousat
Kampong Thom
Kracheh
Mondol Kiri
Pousat
Pousat
Kampong Chhnang
Kampong Cham
Kandal
Kaoh Kong
Kampong Spueu
Prey Veng
Svay Rieng
Takaev
Kampot
Krong Preah Siha
Krong Keab

# សេចក្តីថ្លែងអំណរគុណ

ក្រុមសិក្សាស្តីពីការចិញ្ចឹមជីវិតរបស់ប្រជាជនភូមិកោះឫស្សី ឃុំប្រឡាយមាសស្រុកកំពង់លែង ខេត្តកំពង់ឆ្នាំង សូមថ្លែងអំណរគុណចំពោះ :

-ម្ចាស់គំរោង STREAM ដែលជាអ្នកផ្តល់ការគាំទ្រដល់ក្រុមសិក្សាស្រាវជ្រាវការចិញ្ចឹមជីវិតរបស់ប្រជាជនក្រីក្រ អោយមានដំណើរការពីចាប់ផ្តើមរហូតដល់បានបញ្ចប់ ។

- លោក លោកស្រី ក្រុមសំរបសំរួលកម្មវិធី SCALE បានចុះមកជួយបណ្តុះបណ្តាលអំពីរបៀបស្រាវជ្រាវ ប្រមូល ពតិមាន វិធីសាស្រ្តសំរបសំរួល និង ធ្វើជាអ្នកសង្កេតការផ្តល់នូវប្រឹក្សាល្អៗធ្វើអោយដំណើរការចុះស្រាវជ្រាវ ប្រព្រឹត្តិទៅ ចំគោលបំណងដែលបានគ្រោងទុក ។

ការិយាល័យអភិវឌ្ឍន៍សហគមន៍នេសាទនៃនាយកដ្ឋានជលផលដែលបានសំរបសំរួលអោយមានដំណើរ ការ ។

- អាជ្ញាធរដែនដី ភូមិ ឃុំ ដែលបានបង្កលក្ខណៈងាយស្រួល និង ការប្រមូលផ្តុំអ្នកភូមិ ការស្នាក់នៅ ការ ផ្តល់ពតិមានជំរុញអោយការចុះសិក្សាបានដំណើរការល្អ ។

-ប្រជាជនក្នុងភូមិកោះឫស្សីទាំងអស់ដែលចំណាយពេលវេលាពីកិច្ចការចិញ្ចឹមជីវិតដើម្បីមកចូលរួមផ្តល់ នូវមតិយោបល់ និង ចង្អុលបង្ហាញនៅចំណុចខ្លាំង ចំណុចខ្សោយ សេចក្តីត្រូវការ ភាពរងគ្រោះ និង ការប្រែប្រួលក្នុងមុខ របរចិញ្ចឹមជីវិតរបស់អ្នកភូមិ កត្តាខាងលើនេះបានជំរុញលើកទឹកចិត្តដល់ក្រុមការងារចុះស្រាវជ្រាវបានប្រព្រឹត្តិទៅទទួលបានដំណើរការចប់ចុងចប់ដើម ។

ក្រុមសិក្សា

- លោក អ៊ុយ សោភា ជលផលខេត្តកំពង់ឆ្នាំង
- លោកស្រី ឈុំ ចាន់សុខ កិច្ចការនារីខេត្តកំពង់ឆ្នាំង
- លោក ហួ បូណា ជលផលខេត្តកំពង់ឆ្នាំង
- លោកស្រី ហង្ស ចាន់ថារ៉ា កិច្ចការនារីខេត្តកំពង់ឆ្នាំង
- កញ្ញា ម៉ី ចាន់ធូ មន្ទីរកសិកម្មរុក្ខាប្រមាញ់ និង នេសាទខេត្តកំពង់ឆ្នាំង
- កញ្ញា អ៊ឹង សុលក្ខិណា នាយកដ្ឋានជលផល
- លោក អ៊ឹម សេដ្ឋា ជលផលខេត្តកំពង់ឆ្នាំង

ក្រុមពិគ្រោះយោបល់ ( ស្កេល )

- លោក ហេង ដា
- អ្នកស្រី ឃី ច័ន្ទធារី
- លោក ហ៊ុន ចិន្តា

# មាតិកា

## មាតិកា


សង្ខេប និងសន្និដ្ឋាន ១

**១-បរិបទនៃការសិក្សា**

១.១ ទីតាំងភូមិសាស្ត្រ ៣

១.២ ប្រវត្តិភូមិ ៤

**២-លទ្ធផល**

២.១ ការចាត់ថ្នាក់ទ្រព្យសម្បត្តិ ៧

២.២ ធនធានសំខាន់៧របស់ភូមិ ៩

២.២.១ ធនធានមនុស្ស ៩

២.២.២ ធនធានហេដ្ឋារចនាសម្ពន្ធ័ ៩

២.២.៣ ធនធានធម្មជាតិ ៩

២.២.៤ ធនធានសង្គម ១៣

២.២.៥ ធនធានហិរញ្ញវត្ថុ ១៨

២.៣ ភាពរងគ្រោះ ២០

២.៤ ស្ថាប័ន និង ដំណើរការ ២៥

២.៥ យុទ្ធសាស្ត្រចិញ្ចឹមជីវិត ២៨

២.៦ ការវិភាគដោយយោងទៅតាមគំរោងនិរន្តរភាពនៃការចិញ្ចឹមជីវិត ៣៥

**៣-ការសន្និដ្ឋាន** ៣៥


**តារាង**


តារាង១: ប្រវត្តិកាល ៥

តារាង២: ចំណាត់ថ្នាក់ទ្រព្យសម្បត្តិ ៧

តារាង៣: ធនធានសំខាន់៧របស់ភូមិ ១៩

តារាង៤: ការវិភាគលើស្ថាប័ន និងដំណើរការ ២៥

តារាង៥: ផែនការជួសជុលប្រពន្ធ័ស្រោចស្រព ៣៤


**រូបភាព:**

| | |
|---|---|
| រូបភាពទី១: ទីតាំងស្រុកកំពង់លែង | ២ |
| រូបភាពទី២: ផែនទីកាត់ទទឹង | ១១ |
| រូបភាពទី៣: ផែនទីធនធាន | ១២ |
| រូបភាពទី៤: ផែនទីសង្គម | ១៥ |
| រូបភាពទី៥: វ៉ែនដ្យាក្រាមបុរស | ១៦ |
| រូបភាពទី៦: វ៉ែនដ្យាក្រាមស្ត្រី | ១៧ |
| រូបភាពទី៧: ការប្រែប្រួល | ២៣ |
| រូបភាពទី៨: រដូវកាល បុរស | ៣០ |
| រូបភាពទី៩: រដូវកាលស្ត្រី | ៣១ |
| **រូបភាពទី១០: ការវិភាគបញ្ហា** | ៣៣ |

## សង្ខេប និងសន្និដ្ឋានជាដំបូង

ការសិក្សាស្តីពីការចិញ្ចឹមជីវិតរបស់ប្រជានេសាទ និងកសិករនៅភូមិកោះឫស្សីបានផ្តល់អោយក្រុមយើងខ្ញុំដឹងច្បាស់តាមរយៈនៃការផ្តល់ពិតមានពីដំណើរការរស់នៅរបស់អ្នកភូមិ ។ពួកគាត់ស្ម័គ្រចិត្តចំណាយពេលវេលារយៈពេល ៥ ថ្ងៃចាប់តាំងពីថ្ងៃទី ២៧ ខែ មិថុនា ដល់ថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ ២០០២ ដើម្បីចូលរួម ធ្វើការជាមួយក្រុមយើងខ្ញុំ។ ក្រុមសិក្សាបានធ្វើការជាមួយអ្នកភូមិប្រមាណពី ១៥ នាក់ទៅ ៦០ នាក់ មាន ទាំង បុរស ស្ត្រី ក្មេងចាស់ព្រឹទ្ធាចារ្យ ដែលតំណាងអោយអ្នកភូមិ ទាំង ១៣៥ គ្រួសារ ។

ការសិក្សាបានអនុវត្តទៅតាមកម្មវិធីដែលក្រុមសំរបសំរួលរបស់អង្គការ SCALE បង្ហាត់បង្រៀនតាមវិធីសាស្ត្រ PRA នៅមូលដ្ឋាន និង មានការជួយឧបត្ថម្ភពី STREAM និង DFID ។ ការផ្តល់ពត៌មានជាច្រើននូវសកម្មភាពពីការចិញ្ចឹមជីវិតរបស់អ្នកភូមិ ក្រុមសិក្សាយើងខ្ញុំបានប្រមូលផ្តុំរៀបចំចងក្រង ដើម្បីសរសេរជារបាយការណ៍ ។

គោលបំណងសំខាន់របស់ក្រុមសិក្សាគឺ ដើម្បីផ្តល់លទ្ធភាពអោយអ្នកភូមិកោះឫស្សី ធ្វើការបង្ហាញពីក៏រិតជីវភាពរស់នៅ , ការលំបាក ការទទួលឥទ្ធិពលពីខាងក្រៅ និង សេចក្តីត្រូវការក្នុងពេលបច្ចុប្បន្ន និងពេល អនាគតដល់មជ្ឈដ្ឋានខាងក្រៅ ។

ភូមិកោះឫស្សីមានមុខរបរសំខាន់គឺធ្វើចំការដែលមានផ្ទៃដី ២៩៩ ហិកតា ការនេសាទត្រី និង ធ្វើស្រែប្រាំង ៦១,៨ ហិកតា ។ ក្រៅពីនេះ ពួកគាត់មានមុខរបរបន្ទាប់បន្សំមួយចំនួនទៀតដូចជាការ ត្បាញថែប ជាង ជួសជុល ។ល។

ក៏រិតយល់ដឹងក្នុងការប្រើប្រាស់ជំនាញផ្សេងៗគឺប្រើទៅតាមទំលាប់ចេះត។គ្នាពុំមានការរៀនសូត្រពីបច្ចេកទេសច្បាស់លាស់លើរាល់មុខរបរប្រចាំថ្ងៃរបស់ពួកគាត់ ។

ក្នុងភូមិមានធនធានធម្មជាតិជាច្រើនដូចជាបឹង ១កន្លែង មានទន្លេជាផ្លូវគមនាគមន៏ដ៏សំខាន់ដែលអាចនេសាទត្រីបាន និង ជាប្រភពផ្តល់ទឹកស្រោចស្រព ចំការឬស្រែប្រាំង ។

ទំនៀមទំលាប់ប្រពៃណីសាសនា និង ការជួយគ្នាទៅវិញទៅមកក្នុងពេលមានពិធីឬធុរៈផ្សេងៗក្នុងភូមិពិសេសការប្រវាស់ដៃគ្នារវាងអ្នកមានមធ្យោបាយ និង អ្នកមានកំលាំងពលកម្មក្នុងរដូវធ្វើចំការស្រែ ។ ការការពារប្រភពធនធានធម្មជាតិពួកគាត់បានបង្កើតជាសហគមន៍នេសាទ ដើម្បីទទួលខុសត្រូវនិងគ្រប់គ្រង។ បង្កើតជា គណៈកម្មការភូមិដើម្បីជាបង្អែករឹងមាំ ក្នុងការដោះស្រាយបញ្ហាកើតមានឡើងក្នុងភូមិ។

សកម្មភាពនិងការប្រែប្រួលផ្សេងៗត្រូវបានបង្ហាញក្នុងរដូវកាលលើការងារផ្សេងពីគ្នាឬដូចគ្នារវាង បុរស និងស្ត្រី ។ រីឯការប្រែប្រួលលើធនធាន ពីត្តិការណ៏ផ្សេងៗរបស់ពួកគាត់បានបង្ហាញលើដ្យាក្រាមចំនួន ៨ ស្តីពីបំរែបំរួលកំណើនប្រជាជនការប្រែប្រួលពីផលដំណាំការថយចុះនៃបរិមាណត្រីក្នុងធម្មជាតិការប្រែប្រួលតំលៃកសិផល ការបំផ្លាញនៃសត្វល្អិតលើផលដំណាំ ការប្រើប្រាស់ថ្នាំពុល ការបាក់ដីច្រាំងទន្លេ និង ការ ប្រើប្រាស់គោយន្ត ជាដើម ។

ផលប៉ះពាល់ធ្ងន់ធ្ងរទៅអនាគតដែលគួរអោយព្រួយបារម្ភគឺកំណើនប្រជាជនការបាក់ច្រាំងទន្លេ

សត្វល្អិតបំផ្លាញដំណាំ ផលប៉ះពាល់និងការប្រើប្រាស់ថ្នាំពុលកសិកម្ម ។ ក្រៅពីនេះនៅមានជួបការលំបាកជា ច្រើនទៀត ដូចជាខ្វះទីផ្សារលក់ផលិតផល ដោយឈ្មួញកំណត់តំលៃស្រេចតែចិត្តអត្រាការប្រាក់ខ្ពស់ ខ្វះគ្រូបង្រៀន និង មន្ទីរពេទ្យសំរាប់ព្យាបាលជំងឺនៅឆ្ងាយពីភូមិ ។ កត្តាទាំងនេះជាមូលហេតុបណ្តាលអោយចំនួនអ្នកក្រ និង អ្នកទ័លក្រក្នុង ភូមិកោះឫស្សីមានអត្រាកាន់តែកើនឡើង ចំណែកដីធ្វើស្រែចំការនៅដដែល ។

ក្នុងដំណើរចិញ្ចឹមជីវិតរបស់អ្នកភូមិបច្ចុប្បន្ននេះមានទំនាក់ទំនងជាមួយនឹងស្ថាប័ន ៣ដែលមានឥទ្ធិពលទៅលើ ពួកគាត់ ដូចជា : ស្ថាប័នរដ្ឋាភិបាល , អ្នកជំនួញ និងសង្គមស៊ីវិល ។ ការចាប់អារម្មណ៏សំខាន់ លើបញ្ហា ដែលពួកគាត់ជួបប្រទះ ពិសេសអ្នកទ័លក្រ អ្នកក្រ និង អ្នកមធ្យម មាន១៥បញ្ហា ។ បញ្ហាចំបងដែលត្រូវទាមទារ ធ្វើផែនការដោះស្រាយបន្ទាន់មាន ៤បញ្ហា ។ បញ្ហាទាំងនេះតំរូវអោយមានការជួយឧបត្ថម្ភទាន់ពេលវេលាពីសំណាក់ ស្ថាប័ន រឺអង្គការ នានាខាងក្រៅ ដូច ជាផ្តល់ឥណទាន និង ផ្សព្វផ្សាយបច្ចេកទេសកសិកម្ម ។

ចំពោះផលអវិជ្ជមានឈ្មួញតែងតែបន្ទាបតំលៃផលិតផលកសិកម្មដែលគាត់ធ្វើបាន និង មានអត្រាការប្រាក់ខ្ពស់ នៅពេលដែលពួកគាត់ខ្ចី ។

ផ្អែកតាមពតិមាន និង សកម្មភាពដែលអ្នកភូមិផ្តល់អោយបានបង្ហាញស្ថានភាពរស់នៅផលប៉ះពាល់ និង រាល់បញ្ហាដែលកើតមានឡើងដូចខាងក្រោម :

-គណៈកម្មការសហគមន៏នេសាទ ដែលបានបង្កើតឡើង ពុំទាន់មានសមត្ថភាពក្នុងការគ្រប់គ្រងធនធាន ធម្មជាតិរបស់ខ្លួន ។ ហើយអ្នកភូមិមួយចំនួនធំពុំទាន់យល់ពីអត្ថប្រយោជន៏នៃការបង្កើតសហគមន៏ នេសាទ នៅឡើយ ។

-កិច្ចខិតខំប្រឹងប្រែងរបស់អ្នកភូមិស្ថិតនៅក្រោមឥទ្ធិពលនៃទីផ្សារនិងធម្មជាតិកត្តាទាំងនេះហើយ ដែលជាមូលហេតុបណ្តាលអោយពួកគាត់ក្រីក្រ ។

- ការប្រើប្រាស់ថ្នាំពុល និង ជីគីមី របស់អ្នកភូមិប្រើទៅតាមទំលាប់តៗគ្នា ពុំបានអនុវត្តទៅតាម បច្ចេកទេស ជាហេតុធ្វើអោយប៉ះពាល់ដល់ផលដំណាំ និង សុខភាពពួកគាត់ ។

-ដីភូមិ ដីចំការ និងជំរកត្រី ពងកូនដែលនៅតាមដងទន្លេ បាត់បង់បន្តិចម្តង១ ដោយសាររលកនៃ កប៉ាល់រ៉ូយ៉ាល់ ។

-កំនើនប្រជាជនទ័លក្រ និង ក្រ មានការកើនឡើងជាលំដាប់ ។

# ១. សេចក្តីផ្តើម

## ១.១ ទីតាំងភូមិសាស្ត្រ

ខេត្តកំពង់ឆ្នាំង ជាខេត្តមួយដែលស្ថិតនៅចំកណ្តាលនៃផ្ទៃប្រទេសក្នុងចំណោមខេត្តក្រុងទាំង ២៤ នៃព្រះរាជាណាចក្រកម្ពុជា ដែលមានព្រំប្រទល់ខាងកើតជាប់ខេត្តកំពង់ចាម, ខាងត្បូងជាប់ខេត្តកំពង់ស្ពឺ និង ខេត្តកណ្តាល ខាងលិចជាប់ខេត្តពោធិ៍សាត់ និង ខាងជើងជាប់ខេត្តកំពង់ធំ ។ ខេត្តមានផ្ទៃដីសរុបចំនួន ៥៥២.១០០ហាត ក្នុងនោះផ្ទៃដីសំរាប់ការងារកសិកម្មមានចំនួន ១៣៦.០០០ ហាត ។

យើងអាចធ្វើដំណើរពីក្រុងភ្នំពេញមកខេត្តកំពង់ឆ្នាំងតាមផ្លូវជាតិលេខ៥ មានចំងាយប្រវែង ៩៣ គម បើតាមផ្លូវទឹកវិញយើងអាចជិះទូកតាមទន្លេសាបដែលមានចំងាយប្រវែង ១១០ គម និង ផ្លូវដែក មានចំងាយប្រវែង ៧៣ គម ។ ភ្ញៀវជាតិ និង អន្តរជាតិទាំងឡាយកាលណាឈានជើងចូលមកដល់ខេត្តកំពង់ឆ្នាំងគេតែងតែនាំគ្នាមកទស្សនាភ្នំនាងកង្រី ដែលជាសម្បត្តិវប្បធម៌ដ៏ល្បីល្បាញសំរាប់ខេត្តនេះ ហើយខេត្តមានធនធានសំខាន់មួយទៀតគឺមានទន្លេសាបនិងមួយភាគទៀតជាប់នឹងបឹងទន្លេសាបដែលសំបូរទៅដោយមច្ឆាជាតិគ្រប់ប្រភេទមិនតែប៉ុណ្ណោះមច្ឆាទាំងនេះត្រូវបាននាំចេញទៅប្រទេសក្រៅទៀតផងដែលធ្វើអោយអន្តរជាតិទទួលស្គាល់ថែមទៀតផង ។

ខេត្តកំពង់ឆ្នាំងមានស្រុកចំនួន ៨ ចែកចេញជា ៦៩ ឃុំ និង ៥៤៦ ភូមិ មានប្រជាជនសរុបចំនួន ៤៨៧.៩៩៣ នាក់ ( ជំរឿនជាតិឆ្នាំ ១៩៩៨ ) ។ ក្នុងចំណោមស្រុកទាំង ៨ នេះមានស្រុក ចំនួន៦ ដែលមានដែននេសាទ គឺស្រុកកំពង់ត្រឡាច, ស្រុកជលគីរី, ស្រុករលាប្អៀរ, ស្រុកកំពង់លែង, ស្រុក បរិបូណ៌និង ស្រុកកំពង់ឆ្នាំង ។ យើងបានជ្រើសរើសយកភូមិកោះឫស្សីមកធ្វើការសិក្សាដែលភូមិនេះស្ថិតនៅក្នុងឃុំ ប្រឡាយមាស ស្រុកកំពង់លែង ។

ភូមិកោះឫស្សីជាភូមិដីកោះលិចទឹកនៅរដូវវស្សាមានចំងាយ ១២គម ពីទីរួមខេត្តកំពង់ឆ្នាំង ស្ថិតនៅប៉ែកខាងលិចឈាងខាងជើង ។ ភូមិនេះមានព្រំប្រទល់ខាងកើតជាប់ភូមិកោះក្របី,ខាងលិចជាប់ភូមិស្ទឹងជ្រៅ,ខាងជើងជាប់ភូមិតាដោក និងខាងត្បូងជាប់ភូមិក្រពើពុល ។ ភូមិមានផ្ទៃដីសរុបគឺ ៣៩៩,៣៨ហាត ក្នុងនោះចែកចេញជាដីសំរាប់សង់លំនៅដ្ឋានមានចំនួន ១៤,៥២ ហាត, ដីសំរាប់ធ្វើស្រែប្រាំងមានចំនួន៦១,៨០ហាត, ដីសំរាប់ដាំដំណាំចំការមានចំនួន ២៩៩,២៣ហាត និង ដីទំនេរមានចំនួន ២៣,៨៣ហាត ។ ក្រៅពីនេះមាន ដីដែលកាប់រាននៅក្រៅភូមិតាំងពីឆ្នាំ១៩៧៩ មានចំនួន ៩១,៩៤ ហិកតា , ដីដែលបានទិញបន្ថែមនៅក្រៅភូមិ មានចំនួន ១៣,៤៧ ហាត និងដីដែលបានទៅជួលគេនៅក្រៅភូមិមានចំនួន ១៤៨,៨៩ ហាត ។

## ១.២ ប្រវត្តិភូមិកោះឬស្សី

តាមសំដីរបស់ចាស់ៗព្រឹទ្ធាចារ្យនៅក្នុងភូមិបានរាយរ៉ាប់ពីប្រវត្តិភូមិកោះឫស្សីថា ភូមិនេះមានអាយុប្រហែលជា៦0ឆ្នាំមកហើយ ។ កាលពីដើមឡើយភូមិនេះជាដីកោះដែលសំបូរទៅដោយដើមឬស្សីព្រៃយ៉ាងច្រើន ហើយគ្មានមនុស្សរស់នៅទីកន្លែងនេះជាអចិន្ត្រៃយ៍ទេ គឺមានតែអ្នកធ្វើនេសាទ និង អ្នកកាប់ ឬស្សីមកឈប់សំរាកនៅពេលថ្ងៃតែប៉ុណ្ណោះ ។ នៅពេលនោះភូមិនេះពុំទាន់មានឈ្មោះដូចពេលបច្ចុប្បន្ននេះ ឡើយគឺមានឈ្មោះថា "កោះរាសី" ពីព្រោះគេមានជំនឿថា អ្នកដែលមកនេសាទ ឬ ធ្វើស្រែចំការមកស្នាក់នៅលើកោះនេះតែងតែបានសេចក្តីសុខជានិច្ចពុំមានជួបបញ្ហាឬគ្រោះថ្នាក់អ្វីឡើយ ។ ដើមឬស្សីនៅលើដីកោះនេះបានត្រូវបាត់ម្តងបន្តិចៗដោយសារការប្រើប្រាស់របស់មនុស្សពីគ្រប់ទីកន្លែង ។

លុះក្រោយមកនៅឆ្នាំ ១៩៦0 មានប្រជាជនចំនួន ៤ គ្រួសារ ដែលមានឈ្មោះ តាកឹម យាយពុំ តាប្រាក់ យាយធីម, តាគង់យាយបោះ និងតាហៃ យាយម៉ម អ្នកទាំងអស់នេះបានចាកចេញពីស្រុកកំណើត ឃុំ ស្វាយ ប្រទាល និង ឃុំកោះគរ ស្រុកស្អាង ខេត្តកណ្តាលមកតាំងទីលំនៅបង្កើតជាកូនភូមិតូចមួយមានឈ្មោះថា " ភូមិរាសី " បន្តបន្ទាប់មកពាក្យភូមិរាសីនេះក៏បានក្លាយមកជាភូមិកោះឬស្សីរហូតមកទល់បច្ចុប្បន្ន ។

នៅឆ្នាំ ១៩៧៥ ពួកប៉ុលពតបានជន្លាសអ្នកភូមិទាំងអស់ចេញពីភូមិទៅកាន់តំបន់ផ្សេងៗ លុះបានប៉ុន្មានខែនៅក្នុងឆ្នាំនេះដដែលគេក៏បានអោយអ្នកភូមិមួយចំនួន និង អ្នកភូមិផ្សេងៗទៀតមកនៅក្នុងភូមិនេះវិញដើម្បីធ្វើដំណាំយុទ្ធសាស្ត្រ ។ មកដល់ឆ្នាំ ១៩៧៨ គេក៏បានជន្លៀសអ្នកក្នុងភូមិនេះចេញម្តងទៀតដោយ ឱ្យទៅរស់នៅធ្វើស្រែនៅភូមិថ្មី ឃុំផ្សារ ស្រុកបរិបូណ៌ ខេត្តកំពង់ឆ្នាំង ។

នៅឆ្នាំ ១៩៧៩ ក្រោយថ្ងៃរំដោះប្រជាជនដែលធ្លាប់រស់នៅភូមិនេះពុំទាន់មាននរណាម្នាក់មករស់នៅក្នុងភូមិនេះវិញទេ គឺពួកគេទៅរស់នៅកន្លែងផ្សេងៗគ្នា មួយចំនួនទៅរស់នៅភូមិអំពិលទោល ឃុំពង្រ ស្រុករលាប្អៀរ ។ នៅឆ្នាំ ១៩៨0 ពួកគេទាំងអស់គ្នាបានមករស់ នៅភូមិពាមញរបានប៉ុន្មានខែពួកគាត់ទាំងអស់ ក៏បានចាកចេញទៅរស់នៅភូមិពោធិ៍អណ្តែតបន្តទៀត ។នៅឆ្នាំ ១៩៨១ ពួកគេទាំងអស់បានចុះមករស់នៅ ភូមិប្រឡាយមាស ឃុំប្រឡាយមាស ក្បែរភូមិកោះឬស្សីនេះ ហើយនៅ ឆ្នាំ១៩៨២ ពួកគេទាំងអស់គ្នាបានវិលត្រឡប់មករស់នៅភូមិកោះឬស្សីដែលជាភូមិកំណើតរបស់ខ្លួនវិញ កាលនោះមានប្រជាជនប្រមាណជា ៨0 គ្រួសារប៉ុណ្ណោះ ។

## ប្រតិទិនសង្ខេបព្រឹត្តិការណ៍របស់អ្នកភូមិកោះឫស្សី

តារាងទី១: ប្រវត្តិកាលរបស់ភូមិកោះឫស្សី

| | |
|---|---|
| ១៩៦០ | ភូមិកោះឫស្សីមានប្រជាជនរស់នៅចំនួន ៤ គ្រួសារ អ្នកទាំងនោះចាកចេញពីភូមិស្វាយបន្ទាល ឃុំកោះគរ ស្រុកស្អាង ខេត្តកណ្ដាលមកតាំងទីលំនៅបង្កើតជាកូនភូមិមួយមានឈ្មោះថា ភូមិ រាសី ក្រោយមកដោយសារការហៅឈ្មោះត។គ្នាមក ឈ្មោះភូមិនេះបានក្លាយទៅជាភូមិកោះ ឫស្សី ។ |
| ១៩៧៥ | ជំនាន់ប៉ុលពត អ្នកភូមិត្រូវបានគេជន្លៀសចេញទៅតំបន់ផ្សេង។គ្នា ក្រោយមកនៅក្នុងឆ្នាំដដែលពួកប៉ុលពតបានកំណត់យកភូមិកោះឫស្សីជាភូមិយុទ្ធសាស្ត្រដោយអោយអ្នកភូមិកោះឫស្សីរួមជាមួយអ្នកភូមិផ្សេងទៀតចុះមកធ្វើដំណាំយុទ្ធសាស្ត្រនៅក្នុងភូមិនោះវិញ ។ |
| ១៩៧៩ | នៅក្នុងឆ្នាំនេះប្រជាជនត្រូវបានចាកចេញពីភូមិមករស់នៅតំបន់អំពិលទោល ស្រុករលាប្អៀរ ។ |
| ១៩៨០ | អ្នកភូមិបានត្រឡប់មកពីភូមិអំពិលទោលមករស់នៅភូមិពាមញរមួយរយៈ ក្រោយមកក៏មករស់នៅភូមិពោធិ៍អណ្ដែត ស្រុកកំពង់លែង ។ |
| ១៩៨១ | នៅក្នុងឆ្នាំនេះអ្នកភូមិបានចាកចេញពីភូមិពោធិ៍អណ្ដែតមកនៅភូមិប្រឡាយមាស ឃុំប្រឡាយមាស |
| ១៩៨២ | អ្នកភូមិបានត្រឡប់មកពីភូមិប្រឡាយមាសមករស់នៅភូមិកោះឫស្សីដែលជាភូមិកំណើតរបស់ខ្លួនវិញ ប្រមាណជា ៨០ គ្រួសារ ។ |




រូបភាពទី ១ : ទីតាំងភូមិសាស្ត្រស្រុកកំពង់លែង

# ២. លទ្ធផល

## ២.១ ចំណាត់ថ្នាក់ទ្រព្យសម្បត្តិ

ភូមិកោះឫស្សី គឺជាភូមិមួយដែលមានប្រជាជនរស់នៅប្រមូលផ្តុំគ្នាដោយសង់ផ្ទះជាប់ៗគ្នា ហើយផ្ទះភាគច្រើនធ្វើអំពីឈើប្រក់ក្បឿង សង្កសី និងស្លឹក សង់ខ្ពស់ៗផុតពីដីដើម្បីការពារទឹកជំនន់ ។ បើយើង ក្រឡេកមើលពីខាងក្រៅហាក់ដូចជាប្រជាជនភូមិនេះមានជីវភាពធូរធារគួរសមដែរ ។ ក៏ប៉ុន្តែក្នុងការសិក្សាលើចំណាត់ថ្នាក់ទ្រព្យសម្បត្តិ អ្នកភូមិបានត្អូញត្អែរថាពួកគាត់ភាគច្រើនជាអ្នកក្រីក្រ ហើយគាត់បានបែងចែកស្ថានភាពរស់នៅ របស់ពួកគាត់ជា ៣ ក្រុម គឺ ក្រុមទ័លក្រ ក្រុមអ្នកក្រ និង ក្រុមអ្នកមធ្យម ។

គ្រួសារទ័លក្រមានចំនួន ៧៨ គ្រួសារ គ្រួសារដែលមានជីវភាពក្រ មានចំនួន ៤៩គ្រួសារ និងគ្រួសារដែលមានជីវភាពមធ្យមមានចំនួន ៨ គ្រួសារ ។

តារាងទី២: ចំណាត់ថ្នាក់ទ្រព្យសម្បត្តិប្រជាជនភូមិកោះឫស្សី

| ប្រភេទ | គ្រួសារទ័លក្រ | គ្រួសារក្រ | គ្រួសារមធ្យម |
|---|---|---|---|
| ផ្ទះ | - គ្មានផ្ទះឬនៅជាមួយឪពុកម្តាយ, បងប្អូន ។<br>- ផ្ទះ ឬ ខ្ទមប្រក់ស្លឹក<br>-ផ្លាស់ប្តូរ ឬជួសជុលជារៀងរាល់ឆ្នាំ ។ | - ផ្ទះប្រក់ក្បឿង,ស័ង្កសីជញ្ជាំងបាំងដោយថៃបឬស្លឹក<br>- មានការជួសជុលជារៀងរាល់ឆ្នាំ | - ផ្ទះឈើ ឬ ថ្ម ដំបូលប្រក់ក្បឿងនិង ស័ង្កសី ។<br>- ជញ្ជាំងក្តារ |
| ដីចំការ | - មានពី ០,៣២ ហត ទៅ ១ ហត | - មានដីចំការពី ១ - ២ ហត | - មានពី ២-៥ ហត |
| ឧបករណ៍នេសាទ | - មង ១-២ ដៃ<br>- អង្រុត ១ | - មង ១-៣ ដៃ<br>- អង្រុត ១-២ | - មង ១-២ ដៃ<br>- អង្រុត ១ |
| មធ្យោបាយធ្វើដំណើរ | - ទូក ១ ឬ អាចមានកាណូតតូច ១ | - ទូក ១<br>- កាណូត ១ | - ទូក ១<br>- កាណូត ១-២ |
| សំភារៈកសិកម្ម | ចប,កាំបិត, ពូថៅ | - ចប, កាំបិត, ពូថៅ<br>- គោយន្ត ១ គ្រឿង | - ចប,កាំបិត,ពូថៅ<br>- គោយន្ត ១ គ្រឿង |
| សមាជិកក្នុងគ្រួសារ | មានចំនួនពី៤-១២ នាក់ | មានចំនួនពី ៤-៨ នាក់ | ចំនួន ៤ - ៦ នាក់ |

| | | | |
|---|---|---|---|
| កំលាំងពលកម្ម | កំលាំងពលកម្មតិច( កូនតូចច្រើន ) | មានកំលាំងពលកម្មច្រើន (ជួលកំលាំងបន្ថែម) | មានទុនជួលកំលាំងពលកម្មបន្ថែម |
| ឥណៈទាន | គ្មានការអោយខ្ចីប្រាក់ឬចងការប្រាក់ | អាចចងការប្រាក់ឬ ខ្ចីប្រាក់គេបានដោយមានសំភារៈខ្លះបញ្ចាំ | មានលក្ខណៈងាយស្រួលក្នុងការចងការ ឬ ខ្ចីប្រាក់ |
| សុវត្ថិភាពស្បៀង | ហូបមិនគ្រប់គ្រាន់ | ហូបមិនសូវគ្រប់គ្រាន់ | ហូបគ្រប់គ្រាន់ |
| សុខភាព | - ឈឺច្រើន<br>- កំលាំងខ្សោយ<br>- ហូបមិនគ្រប់គ្រាន់<br>- ជំងឺមិនត្រូវបានព្យាបាលដោយចេះតែទ្រាំ បើធ្ងន់ត្រូវលក់ទូកដើម្បីព្យាបាលជំងឺ ។ | - ឈឺច្រើន<br>- ហូបមិនគ្រប់គ្រាន់<br>- ជំងឺត្រូវបានព្យាបាល | - មិនសូវឈឺ<br>- ហូបគ្រប់គ្រាន់<br>- មានលទ្ធភាពក្នុងការការពារសុខភាពរបស់ខ្លួន ។ |
| សំភារៈប្រើប្រាស់ | - មានវិទ្យុមួយចំនួន | - មានម៉ាញ៉េ, វិទ្យុ<br>- មានទូរទស្សន៍ | - មានម៉ាញ៉េ, វិទ្យុ<br>- មានទូរទស្សន៍<br>- ម៉ាស៊ីនភ្លើង<br>- វិទ្យុទាក់ទង |
| ប្រាក់ចំណូលជាមធ្យមប្រចាំឆ្នាំ | - ពី ៨០០.០០០៛០០ ទៅ ១.០០០.០០០៛០០ | - ពី ២.០០០.០០០៛០០ ទៅ ២.៥០០.០០០៛០០ | ៧.០០០.០០០៛ទៅ ១០.០០០.០០០៛ |

**គ្រួសារទ័លក្រ**

ក្នុងចំណោមអ្នកទ័លក្រចំនួន ៧៨គ្រួសារ មាន៣៣គ្រួសារមិនមានផ្ទះផ្ទាល់ខ្លួនទេដោយពួកគេរស់នៅជាមួយ ឪពុកម្តាយ ឬបងប្អូន ។ ក្រុមនេះភាគច្រើនមានខ្ទម ឬ ផ្ទះទ្រុឌទ្រោម ដំបូលប្រក់ស្លឹកបាំង ជញ្ជាំងថែប ឬស្លឹក ហើយនៅពេលទឹកឡើងលិចភូមិគ្រួសារមួយចំនួនត្រូវបណ្តែតខ្ទមឬផ្ទះលើទឹក ដោយស៊ក ដើមបបោសជំនួសដើមឬស្សី និងមួយចំនួនទៀតទៅរស់នៅបណ្តោះអាសន្នជាមួយឪពុកម្តាយ រង់ចាំទឹកស្រក នឹងវិលមកនៅកន្លែងដើមវិញ ។ ពួកគាត់មានដីចំការតិចតួចដល់ពេលរដូវដាំដុះគាត់ត្រូវជួលដីពីគេនៅក្រៅភូមិដើម្បីធ្វើដំណាំចំការ ដូចនេះចំណូលពីការលក់ផលិតផលត្រូវបែងចែកទៅលើការសងបំណុល និងថ្លៃជួលដីដែលធ្វើឱ្យពួកគាត់ខ្វះខាត ។ ក្នុងការនេសាទពួកគាត់ប្រើឧបករណ៍នេសាទមានមងពី ១-២ ដៃ (១ ដៃ ស្មើ ៦០-៨០ ម ), អង្រុត ១ មងទាំងនេះត្រូវបានពួកគាត់ទិញជឿគេដើម្បីយកមកប្រើប្រាស់ឬឈ្មួញយកមកដាក់អោយ ពេលបានផលត្រូវយកទៅលក់អោយឈ្មួញទាំងនោះ ហើយគេគិត

ទាំងការប្រាក់ក្នុងនោះដែរ ។ ត្រីដែលលក់អោយឈ្មួញទាំងនេះមិនបានថ្លៃទេអាស្រ័យដោយឈ្មួញជាអ្នកកំណត់ថ្លៃ បើយកទៅលក់អោយអ្នកផ្សេងពេលឈ្មួញដឹងគេត្រូវទារយកប្រាក់ជំពាក់ទាំងការទាំងដើមឬរឹបអូសយកសំភារៈដែលមានហើយ ឈប់អោយខ្ចីប្រាក់ និង យកមងមកដាក់អោយដូចមុនទៀត ក្រៅពីឧបករណ៍នេសាទក្រុមនេះមានទូក១ និងអ្នកខ្លះអាចមានដល់ទៅកាណូតផងដែរ ចំពោះការហូបចុកប្រចាំថ្ងៃមានការលំបាកមិនគ្រប់គ្រាន់ព្រមទាំងមិនអាចចងការប្រាក់គេបានដោយគ្មានសំភារៈបញ្ចាំ ។ ក្រុមនេះអាចចងការប្រាក់គេបានដោយអាស្រ័យទៅលើក្រុមគ្រួសារក្រចេញមុខទៅចងការប្រាក់ជំនួសព្រោះក្រុមគ្រួសារក្រអ្នកខ្លះមានសំភារៈបញ្ចាំបាន ។

**គ្រួសារក្រ** : មានផ្ទះនៅដែលមានដំបូលប្រក់ក្បឿង, ស័ង្កសី, ស្លឹក និង ជញ្ជាំងបាំងដោយ ថែប ឬ ស្លឹក ហើយផ្ទះខ្លះមានសរសរធ្វើអំពីថ្ម, មានដីផ្ទាល់ខ្លួនសំរាប់ធ្វើចំការពី ១-២ហត, មានមងពី ១-៣ ដៃ, អង្រុត ១-២ ក្រុមនេះមានលទ្ធភាពជាងក្រុមគ្រួសារទ័លក្រ ដោយពួកគេអាចទិញដោយខ្លួនឯងខ្លះ និង ចងការគេខ្លះ ហើយត្រីដែលគេនេសាទបានពួកគាត់យកទៅកែច្នៃធ្វើ ជាប្រហុក , ផ្អក, ត្រីឆ្អើរ ។ ចំពោះមធ្យោ បាយធ្វើដំណើរក្រុមនេះមានទូកមួយនិងកាណូតមួយ, អាចខ្ចីប្រាក់គេបានដោយមានរបស់ខ្លះអាចបញ្ចាំបាន ។

**គ្រួសារមធ្យម** : មានផ្ទះនៅត្រឹមត្រូវផ្ទាល់ខ្លួន ផ្ទះប្រក់ក្បឿង, ស័ង្កសី និង មានរហូតដល់ ផ្ទះថ្ម ,ការធ្វើផ្ទះរបស់ពួកគេគឺមិនជំពាក់គេដូចគ្រួសារក្រទេ , មានដីសំរាប់ធ្វើចំការពី ២-៥ ហត , មានទូក ១ និង កាណូត ១ ឬ ២ មានលក្ខណៈល្អជាងក្រុមពីរខាងលើ និង មានគោយន្តមួយ ។ មានលក្ខណៈងាយស្រួល ក្នុងការខ្ចីប្រាក់គេ ប៉ុន្តែក្រុមនេះមិនអាចខ្ចីគេទេ ។

## ២.២ ធនធាន

### ២.២.១ ធនធានមនុស្ស

អ្នកភូមិកោះឫស្សីមានកំរិតយល់ដឹងទាបភាគច្រើនមានជំនាញសំខាន់គឺធ្វើចំការ និង នេសាទ ។ ទន្ទឹមនេះមានមុខរបរផ្សេងៗទៀតបន្ទាប់បន្សំដូចជា : ជំនាញជួសជុលទូកកាណូត,ចេះបញ្ចូលអាគុយ,ចេះប្រើប្រាស់គោយន្ត, ជួសជុលតូចទូវគ្រឿងម៉ាស៊ីន,ចេះត្បាញថែប, ធ្វើលប, កែច្នៃផលិតផលដំណាំ, កែច្នៃផលនេសាទ និង ចិញ្ចឹមត្រី ។ ក្រៅពីនេះនៅមានឆ្មបបូរាណ ១នាក់ ពេទ្យភូមិ ១ នាក់, គ្រូបង្រៀន ៥នាក់មកពីក្រៅភូមិ, មានអាចារ្យ, មានអ្នកកាត់ដេរ ៦នាក់ដែលអាចរកប្រាក់កំរៃបានពី ២០ $ - ៤០ $ មានមេភូមិទំនាក់ទំនងខាងក្រៅភូមិជាបង្អែកយ៉ាងមាំរបស់ប្រជាជន ។

### ២.២.២ ធនធានហេដ្ឋារចនាសម្ព័ន្ធ

ភូមិកោះឫស្សីមានផ្លូវលំមួយខ្សែ សំរាប់ទំនាក់ទំនងជាមួយភូមិជិតខាង និង ផ្លូវទឹកព័ទ្ធជុំវិញអាចធ្វើចរាចរបានទាំងរដូវប្រាំង និង វស្សា, សាលារៀន ១ខ្នង មាន ៥បន្ទប់ ទទួលសិស្សចូលរៀនបានពី ១៥០-២០០នាក់, មានតូបលក់ចាប់ហួយ ៦ កន្លែង ជាងដែក ១កន្លែង, កន្លែងសាកអាគុយ ១កន្លែង និង សាលាបុណ្យ មួយកន្លែងសំរាប់ប្រារព្ធពិធីបុណ្យទានផ្សេងៗក្នុងភូមិ ។

### ២.២.៣ ធនធានធម្មជាតិ :

ក្នុងភូមិកោះឫស្សីមានផ្ទៃដីសរុប ១៩១,៥ ហាត ក្នុងនោះដីសំរាប់សង់លំនៅដ្ឋានមានចំនួន ១០,៨ ហាត ដីសំរាប់ធ្វើ ដំណាំចំការមានចំនួន១៧៤ហាត, ដីស្រែប្រាំងចំនួន ៥ហាត,ដីព្រៃលិចទឹកចំនួន៥ហាតព័ទ្ធជុំវិញបឹង,មានបឹងមួយកន្លែងសំរាប់ធ្វើនេសាទនៅរដូវប្រាំង និង ប្រើប្រាស់ទឹកសំរាប់ស្រោចស្រប់ដំណាំនៅរដូវប្រាំង ធនធានទាំងនេះត្រូវបានប្រជាជនប្រើប្រាស់ក្នុងការប្រ កបរបរចិញ្ចឹមជីវិត ក្រៅពីនេះមានសត្វព្រៃដូចជា ពស់, អណ្តើក ។ល។

តាមការសិក្សាលើផែនទីបានអោយដឹងថា ផ្ទៃដីសរុបដែលភូមិមានគឺ ៣៩៩,៣៨ ហាត ក្នុងនោះចែកចេញជាដីសំរាប់ សង់លំនៅដ្ឋានមានចំនួន១៤,៥២ ហាត, ដីសំរាប់ធ្វើស្រែប្រាំងមានចំនួន៦១,៨០ហាត,ដីសំរាប់ដំណាំចំការមានចំនួន ២៩៩,២៣ហាត និង ដីទំនេរមានចំនួន ២៣,៨៣ហាត ។ ក្រៅពីនេះមានដីដែលកាប់រាននៅក្រៅភូមិតាំងពីឆ្នាំ ១៩៧៩ មានចំនួន ៩១,៩៤ ហិកតា, ដី ដែលបានទិញបន្ថែមនៅក្រៅភូមិមានចំនួន ១៣,៤៧ ហាត និង ដីដែលបានទៅជួលគេនៅក្រៅភូមិមានចំនួន ១៤៨,៨៩ ហាត ។

# គំនូសផែនទីកាត់ទទឹងភូមិកោះឫស្សី



| | ទន្លេមុខភូមិ | ដីភូមិ | ដីទំនេរ | ដីទំនាប | បឹង | ដីទំនាប | ដីទួល | ទន្លេក្រោយភូមិ |
|---|---|---|---|---|---|---|---|---|
| សណ្ឋានដី | | | | | | | | |
| ប្រភេទដី | | កណ្តុល ល្បាយខ្សាច់ | កណ្តុល | កណ្តុល | | កណ្តុល | កណ្តុល | |
| ដំណាំចំបង | | ងាត, អំពៅ ម្ទេស | | ដំណាំចំការ និង ស្រូវ | | ដំណាំចំការ | ដំណាំចំការ | |
| សត្វចិញ្ចឹម និងសត្វព្រៃ | ចិញ្ចឹមត្រី តាមបៃ | មាន់ | | | | | | |
| ការប្រកបរបរ | នេសាទ | ដំណាំរួមផ្សំ | អោយគេព្រាផុះ ដើម្បីការពារទឹក ជំនន់ និង ខ្យល់ | ធ្វើដំណាំចំការ និង ស្រូវ | នេសាទនិង យកទឹកធ្វើ ការស្រោច ស្រប់ដំណាំ | ធ្វើដំណាំចំការ | ធ្វើដំណាំចំការ | នេសាទ |
| បញ្ហា | បាក់ដីច្រាំង | | បានដំណាំតិច | សត្វល្អិត និង កណ្តុរ | បង្ហូរទឹក ចាប់ត្រី | សត្វល្អិត និង កណ្តុរ | សត្វល្អិត និង កណ្តុរ | |

រូបភាពទី ២: ផែនទីកាត់ទទឹងភូមិកោះឫស្សី




រូបភាពទី ៣: ផែនទីការប្រើប្រាស់ដី

## ២.២.៤ ធនធានសង្គម

ផ្ទះរបស់អ្នកភូមិសង់ស្ទើរតែជាប់ៗគ្នាដែលជាវិធីសាស្រ្តទប់ទល់នឹងខ្យល់នៅរដូវវស្សារបស់អ្នកភូមិ តែវាក៏ជាការបង្ហាញថាអ្នកភូមិរស់នៅក្នុងភាពសាមគ្គីជិតស្និទ្ធ ហើយមានភាពងាយស្រួលក្នុងការងារទំនាក់ទំនងពេលមានបញ្ហា ។ គេមានជំនឿសាសនាតែមួយគឺសាសនាព្រះពុទ្ធ ដែលលើកទឹកចិត្តឱ្យអ្នកភូមិរស់នៅរួបរួមគ្នាមិនបៀតបៀនអ្នកដទៃ។ លើការងារគ្រប់គ្រងភូមិមានគណៈកម្មការភូមិ និងគណៈកម្មការសហគមន៍នេសាទដែលទើបនឹងបង្កើត។ គណៈកម្មការភូមិមានតួនាទី មើលការងារទូទៅ និង ដោះស្រាយបញ្ហាផ្សេងៗដែលកើតមានឡើងនៅក្នុងភូមិ ឯសហគមន៍នេសាទផ្តោតសំខាន់ទៅលើការគ្រប់គ្រងថែទាំធនធានធម្មជាតិ ។

ក្នុងការងារបង្កបង្កើនផលអ្នកភូមិនិយមរបៀបប្រវាស់ដៃជួយគ្នាទៅវិញទៅមក ដូចជាអ្នកក្រីក្រដែលគ្មានម៉ាស៊ីនគោយន្តកាត់ស្មៅឬភ្ជួរដីអាចធ្វើការឱ្យគេ៤ថ្ងៃ ដើម្បីឱ្យគេកាត់ស្មៅឱ្យមួយថ្ងៃវិញ ហើយនៅពេលម៉ាស៊ីនខូចបន្តិចបន្តួចគេជួយជួសជុល ដោយមិនគិតថ្លៃ។

ដើម្បីការយល់ដឹងបន្ថែមទៅលើការទំនាក់ទំនងសង្គម ក្រុមសិក្សាបានធ្វើការសិក្សាដាច់ដោយឡែកពីគ្នារវាងក្រុមបុរស និងស្រ្តី (សូមមើលដ្យាក្រាម បុរស និង ស្រ្តី) ។

ក្នុងការសិក្សាលើការទំនាក់ទំនងជាមួយស្ថាប័នផ្សេងៗដែលពាក់ពន្ធ័នឹង ប្រជាជននៅភូមិនេះក្រុមអ្នកសិក្សាបានសំរបសំរួលឱ្យអ្នកភូមិប្រើទំហំក្រដាស់រាងរង្វង់ដែលមានទំហំបីខុសគ្នា : ស្ថាបន័ ឬបុគ្គលដែលសំខាន់តាងដោយក្រដាស់ធំជាងគេទំហំមធ្យមសំរាប់ស្ថាបន័ឬបុគ្គលដែលមានតួនាទីសំខាន់បន្ទាប់ និង តូចជាងគេសំរាប់អ្នកមិនសូវសំខាន់ ។ រីឯចំងាយបង្ហាញពីភាពជិតស្និត ឬ ចេញចូលញឹកញាប់ជាមួយអ្នកភូមិ ។ នៅក្នុងដ្យាក្រាមទាំងពីរបានបង្ហាញឱ្យឃើញថា អ្នកភូមិទាំងបុរសនិងស្ត្រីមានការទំនាក់ទំនងជាមួយនឹងបុគ្គល ឬ ស្ថាបន័មួយចំនួនដូចគ្នាដូចជា ក្នុងចំណោមអ្នកដែលមានទំនាក់ទំនងជិតស្និទ្ធ និង សំខាន់បំផុត ពួកគាត់បានជ្រើសរើសយកមេភូមិ អាចារ្យក្រុមប្រឹក្សាមេឃុំ ពេទ្យឃុំ ឆ្មបបូរាណ ឥណទាន និងសហគមន៍នេសាទ ។ មេភូមិជាអ្នកជួយការងារទំនាក់ទំនងទៅនឹងអាជ្ញាធរថ្នាក់ស្រុកឬខេត្តនិងជួយដោះស្រាយបញ្ហានៅក្នុងភូមិ ធ្វើការទំនាក់ទំនងជាមួយគាត់បានឆាប់ រហ័ស ។ អាចារ្យមានតួនាទីសំខាន់ក្នុង ការចាត់ចែងពិធីបុណ្យប្រពៃណីផ្សេងៗ។ មេឃុំក៏ដូចជាប្រធានភូមិដែរទាំងនៅជិតអ្នកភូមិ និង ងាយស្រួលទំនាក់ទំនង ហើយធ្វើការងារដែលប្រធានភូមិមិនអាចសំរេចបាន ។ នៅក្នុងភូមិមិនមានពេទ្យឆ្មបទេការសំរាលកូនគឺពឹងផ្អែកទាំងស្រុងទៅលើឆ្មបបុរាណដូចនេះទាំងបុរសនិងស្ត្រីចាត់ទុកថាគាត់សំខាន់ ។ ទោះបីជានៅក្នុងភូមិនេះមិនមានអង្គការណាមួយមកធ្វើឥណទានក៏ដោយ ក៏អ្នកភូមិបានសំរេចថាស្ថាប័នឥណទាននេះសំខាន់ ហើយជិតស្និទ្ធដែរដោយសារគាត់ធ្លាប់ទៅខ្ចីលុយពីអង្គការប្រាសាក់ដែលធ្វើនៅភូមិជិតខាង ។ សហគមន៍នេសាទដែលទើបបង្កើតមាន

សារៈសំខាន់សំរាប់គាត់ ព្រោះកន្លងមកមុនពេលពុំទាន់មានសហគមន៍ អ្នកភូមិមានបញ្ហាជាមួយឈ្មួញក្នុងការប្រើប្រាស់ទឹកបឹងសំរាប់ធ្វើស្រែប្រាំងនៅពេលមានសហគមន៏អ្នកភូមិអាចប្រើប្រាស់ទឹកបឹងនេះបានវិញ ។

ក្រុមស្ត្រីបានគិតគូរថាប្រធានក្រុមសំខាន់នៅពេលដែលបុរសមិនបានយកចិត្តទុកដាក់លើចំនុចនេះ។ ស្ត្រីយល់ថា ប្រធានក្រុមជាអ្នកជួយសំរួលការងាររវាងគាត់និងប្រធានភូមិ ដែលមិនចាំបាច់ឱ្យគាត់ទៅទាក់ទងប្រធានភូមិដោយផ្ទាល់ ។ ក្រៅពី នេះគាត់បានគិតគូរទៅលើស្ថាបន័ សំខាន់ៗមួយចំនួនដែលនៅឆ្ងាយៗ ហើយស្ទើរតែមិនធ្លាប់ឃើញមកដល់ ភូមិគាត់ ដូចជា ថ្នាក់ស្រុក កសិកម្ម រដ្ឋាភិបាល។

បុរសបានចាត់ទុកថា សាលារៀនសំខាន់សំរាប់ឱ្យកូនចៅគាត់ទៅរៀន តែនារីមិនបានគិតគូលើបញ្ហានេះ ហើយបុរសក៏មានការគិតគូរទៅលើឈ្មួញ ទីផ្សារ និង វត្តអារាម នៅពេលដែលស្ត្រីមិនគិតថាសំខាន់សំរាប់គាត់ព្រោះថានារី មិនសូវមានលទ្ធភាព បើកកាណូតទៅផ្សារដូចនេះបុរសត្រូវធ្វើការងារនេះច្រើន ។




រូបភាពទី ៤: ផែនទីសង្គម







រូបភាពទី ៥: វ៉ែនដ្យាក្រាមបុរស និង ស្ត្រី

### ២.២.៥ ធនធានហិរញ្ញវត្ថុ

ប្រភពចំណូលសំខាន់ៗរបស់អ្នកភូមិគឺបានមកពីការលក់ផលិតផលកសិកម្មដូចជា ពោត សណ្តែក ម្ទេស ឪឡឹក ត្រប់ និងបន្លែផ្សេងៗ និង ផលនេសាទ ។ ប្រាក់ចំណូលរបស់អ្នកទ័លគឺបានមកពីការនេសាទ ច្រើនជាងការលក់កសិផលដែលជាមធ្យមមួយគ្រួសារអាចបានប្រាក់ពី ៨០-៩០ម៉ឺនរៀល/ឆ្នាំ អ្នកក្របានមកពីកសិផលច្រើនជាង គឺពី ២-២.៥ លានរៀល/ឆ្នាំ ហើយអ្នកមធ្យម វិញគេមិនសូវធ្វើនេសាទទេ ចំការជា មុខរបរសំខាន់បំផុតរបស់គេហើយគេអាចបានចំណូលរហូតដល់ ពី ៧-៨ លានរៀល/ឆ្នាំ ។

ក្រៅពីនេះអ្នកទ័ល និងអ្នកក្រអាចធ្វើការលក់ពលកម្មនៅក្នុងភូមិដូចជាការកាត់ស្មៅវាយសណ្តែកកាប់ព្រៃជំរះស្មៅ ដែលបានចំណូល ពី ៣៥០០-៤០០០រៀល/ថ្ងៃ ។ អ្នកដែលមានម៉ាស៊ីនគោយន្តអាចស៊ី ឈ្នួលកាត់ស្មៅបាន ៥០០០០-៦០០០០រៀល ក្នុងមួយថ្ងៃ ។ នៅរដូវទឹកតំឡើងគេអាចទៅរកអុសអណ្តែតតាមទឹក ទន្លេយកទៅលក់បានពី ២០០០-៣០០០រៀល/ថ្ងៃ ។ ក្រៅពីនេះចំណូលតាមរយៈការងាររោងចក្រកាត់ដេរអាចបានកំរៃបន្ថែមមធ្យមប្រចាំខែក្នុងម្នាក់ពី ២០ $-៤០ $ ។ នៅមានមុខរបរបន្ទាប់ បន្សំមួយចំនួនទៀតដូចជា ការត្បាញថែប, បញ្ចូលអាគុយ,ការជួសជុលទូកកាណូត, ការជួសជុលផ្ទះ អាចបង្កើនចំណូលមួយចំណែក ថែមទៀត ។

ទោះបីជាអ្នកភូមិមួយចំនួនបានប្រាក់ចំណូលពីការលក់កសិផលយ៉ាងច្រើនដូចនេះក៏ដោយក៏ពួកគាត់នៅតែមានការ ខ្វះខាតច្រើនដែរ ជាពិសេសក្នុងប៉ុន្មានឆ្នាំចុងក្រោយនេះ គាត់ត្រូវចំណាយប្រាក់ច្រើនលើការទិញថ្នាំសំលាប់សត្វល្អិត ហើយការប្រើថ្នាំសត្វល្អិតច្រើននេះប៉ះពាល់ដល់សុខភាព ដែលធ្វើឱ្យគាត់ចំណាយប្រាក់កាន់តែច្រើន លើការព្យាបាល ។ កត្តានេះហើយដែលធ្វើឱ្យគាត់ត្រូវទៅខ្ចីបុលគេ គាត់អាចខ្ចីគេបានក្នុងអត្រាការប្រាក់ពី ១០-១៥ %/ ខែ ហើយអាចខ្ចីបានត្រឹម ៣០ម៉ឺនរៀល និង អ្នកទល់មិនអាចខ្ចីលុយគេបានឡើយ ។

តារាងទី៣: ធនធានសំខាន់ៗរបស់ភូមិកោះឬស្សី

| ធនធានមនុស្ស | ធនធានហេដ្ឋារចនាសម្ព័ន្ធ | ធនធានធម្មជាតិ | ធនធានសង្គម | ធនធានហិរញ្ញវត្ថុ |
|---|---|---|---|---|
| - សិស្សសាលា | - មានផ្លូវទឹកសំរាប់ធ្វើដំណើរ | - មានទន្លេព័ទ្ធជុំវិញភូមិ | - គណៈកម្មការភូមិ | - លក់ផលិតផល |
| - ចេះធ្វើស្រែ និង ចំការ | - សាលាបឋមសិក្សា ១ ខ្នង | - មានបឹងមួយកន្លែង | - សហគមន៍នេសាទ | - លក់ផលនេសាទ |
| - ចេះនេសាទត្រី និង កែច្នៃ | - ផ្លូវលំមួយខ្សែ | - មានដីចំការ | - កំលាំងប្រវាស់ដៃ | - តំលៃពលកម្ម (២០០០៛-៤០០០៛) |
| - ជាងធ្វើទូកកាណូត | - តូបលក់ចាប់ហួយ ៦ កន្លែង | - មានដីស្រែប្រាំង | - ការសាមគ្គីក្នុងភូមិ | - ជួលគោយន្ត |
| - ឆ្មបបូរាណ ១ នាក់ | - កន្លែងសាកអាគុយ | - មានសត្វព្រៃ | - សាសនាព្រះពុទ្ធ | - កាប់អុស |
| - អ្នកបើកគោយន្ត | - កន្លែងជាងដែក | - មានព្រៃត្រែង | - អ្នកស៊ីឈ្នួលគេ | - លក់ចាប់ហួយ |
| - ចិញ្ចឹមត្រី ៣ គ្រួសារ | - សាលាបុណ្យ | - មានដីទុកនៅទំនេរ | | - ធ្វើថែបលក់ |
| - ជាងធ្វើម៉ាស៊ីន(ជួសជុល) | | - មានព្រៃកាប់អុស | | - កម្មករកាត់ដេរ |
| - អ្នកទៅកាត់ដេរ | | - មានព្រៃលិចទឹក | | |
| - អ្នកត្បាញថែប | | | | |
| - មេភូមិដឹកនាំ | | | | |
| - អាចារ្យ | | | | |
| - អ្នកធ្វើលប ១ នាក់ | | | | |
| - អ្នកបញ្ចូលអាគុយ ១ នាក់ | | | | |
| - គ្រូពេទ្យភូមិ ១ នាក់ | | | | |
| - ជាងដែក | | | | |

## ២.៣ គាពរខគ្រោះ

### *២.៣.១ កសិកម្មនិងរដូវកាល*

សកម្មភាពបង្កបង្កើនផល ការងារសង្គម និង ការប្រែប្រួលក្នុងរយៈពេលមួយឆ្នាំត្រូវបានបង្ហាញនៅក្នុងដ្យាក្រាមរដូវកាលដែលធ្វើឡើងដោយក្រុមបុរសនិងស្ត្រីដាច់ដោយឡែកពីគ្នា ។ ក្រុមសិក្សាបានសំរបសំរួលឱ្យអ្នកភូមិដាក់គ្រាប់ពោតដើម្បីសំគាល់ភាពរវល់ មិនសូវរវល់តាមខែនិមួយៗ ដោយកំណត់ថា ៥គ្រាប់រវល់ខ្លាំង ហើយមិន សូវរវល់ ៤ ឬ ៣ ទៅតាមលំដាប់រហូតដល់មិនមានសកម្មភាពសោះដោយទុក នៅទំនេរ ។ ក្រុមទាំងពីរបានជ្រើសរើស យកខែតាមប្រតិទិនចន្ទគតិ ដែលគេនិយមហៅថាខែខ្មែរមកប្រើ ដោយចាប់ផ្តើមពីខែអស្សុជ ត្រូវនឹងខែ ១០-១១ នៃខែ សាកល ។ នៅក្នុងខែមាឃ-បុស្ស ដែលត្រូវនឹងខែ១២និងខែ១ខែសាកលអ្នកភូមិទាំងបុរសស្ត្រីមានការមមាញឹកយ៉ាងខ្លាំងជាងគេក្នុងនោះមានការដាំដំណាំដូចជាសណ្តែកបាយឪឡឹកថ្នាំជក់ ម្ទេស ត្រប់ ល្ពៅ និង ស្រូវប្រាំង ។ល។ នៅក្នុងពេលនោះដែរក៏ជាពេលដែលអ្នកភូមិទូទៅត្រូវធ្វើការនេសាទ ព្រោះជារដូវសំបូរត្រីជាពេលដែលត្រូវចាប់ត្រីដើម្បីធ្វើ ការកែច្នៃទុកនិងជាពេលដែលអាចចាប់ត្រីលក់យកប្រាក់ទៅធ្វើស្រែចំការដែលត្រូវចំណាយដើមទុនច្រើននៅពេលនេះ ។ចាប់ពីខែបុស្សដល់ខែ មាឃ ( មករាកុម្ភៈ) គឺជាការងារថែទាំដំណាំ ក្រុមបុរសច្រើនធ្វើការបាញ់ថ្នាំសំលាប់សត្វល្អិត ឯនារីវិញច្រើនធ្វើការជំរះស្មៅ ។ ពេលនេះគាត់អាចប្រមូលផលដំណាំលក់ខ្លះៗ ជាពិសេសត្រសក់ ។

ចាប់តាំងពីខែផល្គុន-ចេត្រ គាត់អាចបន្តប្រមូលផលដំណាំផ្សេងៗទៀត ដូចជា ឪឡឹកសណ្តែកបាយ ម្ទេស ហើយដំណាំម្ទេសនេះបើគ្មានការបំផ្លាញពីសត្វល្អិតទេ គាត់អាចបន្តប្រមូលផលរហូតដល់ទឹកឡើងលិច គឺនៅប្រ ហែលខែ ជេស្ឋ ឬអាសាធ ។ ជាទូទៅគេនិយមដាំពោត ចាប់ពីខែពិសាខ ឬ ជេស្ឋ អាស្រ័យទៅតាមទឹកភ្លៀងឆាប់ធ្លាក់គេឆាប់បានដាំ ។ ដំណាំពោតនេះគេដាំនៅលើដីស្រូវប្រាំងសណ្តែកបាយ និងដំណាំផ្សេងៗទៀតដែលប្រមូលផលបញ្ចប់នៅក្នុងខែចេត្រហើយការដាំពោតនេះអាចបានផលឬអត់នោះវាអាស្រយ័ទៅលើធម្មជាតិទាំងស្រុងព្រោះថាបើភ្លៀងធ្លាក់យឺតពេលហើយទឹកទន្លេឡើងលឿននោះវានឹងលិចខូចអស់ ។ នៅក្នុងខែនេះក៏ជាពេលដែលអ្នកភូមិមានការមមារញឹកខ្លាំងណាស់ដែរហើយមិនអាចខកខានបានទេ គាត់ត្រូវកាត់ស្មៅនិងព្រៃតូចៗដែលដុះលើដីចំការគាត់ឱ្យបានមុនទឹកលិចហើយស្មៅនេះគាត់ត្រូវធ្វើយោងទៅលើល្បឿនទឹកទន្លេឡើងព្រោះបើកាប់ហើយទឹកក្រឡើងលិចដីនេះស្មៅនឹងដុះឡើងវិញដដែល ។ នៅខែស្រាពនិងខែភទ្របុទ អ្នកភូមិទាំងបុរសស្ត្រីនាំគ្នាអូសកំប្លោកចូលចំការសំរាប់ប្រើប្រាស់នារដូវ ទឹកសំរក និង ឆ្លៀតឱកាសរកអុសទុកសំរាប់ដុត ។ ចាប់ពីខែ បុស្ស ដល់ខែមាឃ ត្រូវនឹងខែ មករានិងខែកុម្ភៈអ្នកភូមិមានការរវល់ខ្លាំងក្នុងការការពារទប់ទល់និងសត្វល្អិតបំផ្លាញដំណាំ ។ ក្រៅពីនេះពួកគាត់នៅមានការងារកែច្នៃផលដំណាំដូចជា ហាន់ថ្នាំជក់, ឆ្អើរម្ទេស, ហាលពោតទុកពូជសំរាប់ឆ្នាំក្រោយ ។ អ្នកភូមិគាត់អាចរកប្រាក់ចំណូលចាប់ពីខែ មិគសិរដល់ខែមាឃ ( ខែ ១២ដល់ខែ ២ ) គឺគាត់លក់ត្រីស្រស់ និង ត្រីឆ្អើរទទួលបានចំណូលខ្លះអាចអោយគាត់ដោះ ស្រាយបានមួយចំណែក ។

# ប្រតិទិនរដូវកាល

| ខែ / សកម្មភាព | ១ បុស្ស | ២ មាឃ | ៣ ផល្គុន | ៤ ចេត្រ | ៥ ពិសាខ | ៦ ជេស្ឋ | ៧ អាសាឍ | ៨ ស្រាពណ៍ | ៩ ភទ្របទ | ១០ អស្សុជ | ១១ កត្តិក | ១២ មិគសិរ |
|---|---|---|---|---|---|---|---|---|---|---|---|---|
| ឃ្លោក, ឪឡឹក, ត្រឡាច, ត្រសក់, ប្រហោក់ជ្រូវ ស្ពៃប្រាំង, ប៉េងប៉ោះ, ល្ង, ឃ្លោកអង្គុយ | ●●●● ដាំ | ●●●● ថែទាំ | ●●●●● ប្រមូលផល | | | | | | | | | ●●●●● ដាំ |
| ថ្នាំជក់, ល្ពៅ | ●●● ដាំ | ●● ថែទាំ ចាក់ថ្នាំ | ●●● ប្រមូលផល | ●●● ប្រមូលផល | ●●● ប្រមូលផល | | | | | | | |
| ក្ដួច និង ត្រាវ | ●●●●● ដាំ | ●●● ថែទាំ | ●● ថែទាំ | ● ថែទាំ | ● ប្រមូលផល | ●●●●● ប្រមូលផល | ●● ប្រមូលផល | | | | | |
| ស្រូវ | | | | | ●●●●● ដាំ | ● ថែទាំ | ●●● ប្រមូលផល | | | | | |
| នេសាទត្រី, ងៀតត្រី, ធ្វើប្រហុក-ផ្អក | ●●●●● | ●●●● | ● | ● | ● | ● | ● | ●● | ●● | ●●● | ●● | ●●●●● |
| បោសស្មៅ និង បាចថ្នាំជក់ | | | | ● | ●●●● | ●●●● | | | | | | |

## ប្រតិទិនរដូវកាល

| ខែ / សកម្មភាព | ១ បុស្ស | ២ មាឃ | ៣ ផល្គុន | ៤ ចេត្រ | ៥ ពិសាខ | ៦ ជេស្ឋ | ៧ អាសាឍ | ៨ ស្រាពណ៍ | ៩ ភទ្របទ | ១០ អស្សុជ | ១១ កត្តិក | ១២ មិគសិរ |
|---|---|---|---|---|---|---|---|---|---|---|---|---|
| កាប់ព្រៃ និង ស្មៅពន្លិចទឹក | | | | | | ●●●●● | ●●●●● | | | | | |
| ត្រសក់ផ្លាក | | | | | | | | ●●●●● | ●● | | | |
| ទកត្រសដុត | | | | | | | ●●● | ●●● | ●●● | | | |
| ប្រព្យែប | | | | | | | | | | | ●●● | |
| ពុលឬស្សីធ្វើថ្នាំលាបក្រាប់ពុង | | | | | | | | | | | ●●●● | |
| ទឹកឡើង | | | | | ● | ●● | ●●●●● | ●●●●● | ●● | | | |

រូបភាពទី ៦: ប្រតិទិនរដូវកាល

## ២.៣.២ និន្នាការ ឬ ការប្រែប្រួល

និន្នាការ ឬ ការប្រែប្រួលបានកើតមានឡើងនៅភូមិកោះឫស្សី កើតមានឡើងជាច្រើនកត្តា ។ កត្តាទាំងនេះគាត់បានបង្ហាញពីការប្រែប្រួលដោយដ្យាក្រាមចំនួន ៨ គឺកំណើនប្រជាជន, ទិន្នផលដំណាំ, ការថយចុះនៃ បរិមាណត្រីក្នុងធម្មជាតិ, ការប្រែប្រួលតំលៃកសិកផល, ការបំផ្លាញនៃសត្វចង្រៃ, ការប្រើប្រាស់ថ្នាំពុល, ការប្រើប្រាស់ គោយន្ត និង ការបាក់ដីច្រាំងទន្លេ ។

- ការប្រែប្រួលនៃចំនួនប្រជាជន : នៅឆ្នាំ ១៩៧០ ប្រជាជនភូមិកោះឫស្សីមានចំនួន ១២០ គ្រួសារ មកដល់ឆ្នាំ ១៩៧៥ នៅសម័យប៉ុលពតភូមិនេះមានប្រជាជនរស់នៅចំនួន ៧៥ គ្រួសារ ។ នៅឆ្នាំ ១៩៨០ ភូមិកោះឫស្សី គ្មានមនុស្សមករស់នៅទេគឺមានតែអ្នកមករកនេសាទ ឬ កាប់អុសចំនួនបួនទៅប្រាំនាក់ប៉ុណ្ណោះ ព្រោះតំបន់នេះជាកន្លែងកាន់កាប់របស់ពួកខ្មែរក្រហម ដូចនេះគ្មានប្រជាជនណាហ៊ានមករស់នៅក្នុងភូមិនេះឡើយ លុះឈានចូលមកឆ្នាំ១៩៨២ ភូមិនេះមានប្រជាជនចំនួន៨០ គ្រួសារ បានវិលត្រឡប់មករស់នៅវិញ ។ ការរស់នៅរបស់ពួកគេពេល នោះមានការ ភិតភ័យជាមួយខ្មែរក្រហមយ៉ាងខ្លាំង ប៉ុន្តែដោយមានគោលជំហរ សាមគ្គីគ្នា និង ការតស៊ូរបស់ពួកគេ បានធ្វើអោយពួក ខ្មែរក្រហមនៅទីនោះត្រូវចាកចេញទៅនៅកន្លែងផ្សេង វិញ ។ ក្រោយមកនៅឆ្នាំ ១៩៩០ ប្រជាជននៅភូមិនេះមាន កំណើនរហូតដល់ ១១៦គ្រួសារ ដែលការកើន ចំនួននេះបណ្តាលមកពីការបែកគ្រួសារ និងមានកូនចៅរើកសាយកាន់តែ ច្រើន ។ នៅឆ្នាំ ២០០០ប្រជាជនកើនឡើងរហូតដល់ចំនួន១២០គ្រួសារនិងឈានមកដល់ឆ្នាំ២០០២(បច្ចុប្បន្ន) ប្រជាជនមានចំនួន ១៣៥គ្រួសារ ។

- ការថយចុះនៃបរិមាណត្រីក្នុងធម្មជាតិ : នៅឆ្នាំ ១៩៧៩ មច្ឆាជាតិនៅក្នុងធម្មជាតិសំបូរដល់កំរិត អតិបរមា ប៉ុន្តែមច្ឆាទាំងនេះត្រូវបានថយចុះបន្តិចម្តងៗដោយសារការប្រើប្រាស់មនុស្ស ។ នៅឆ្នាំ១៩៨៥ត្រីក្នុងធម្ម ជាតិមានប្រមាណជា ៨០ % បើប្រៀបធៀបទៅឆ្នាំ ១៩៧៩ ហើយបរិមាណត្រីចេះតែមានការថយចុះជាលំដាប់រហូត មកដល់ឆ្នាំ ១៩៩៥ ត្រីក្នុងធម្មជាតិបានថយចុះមកនៅត្រឹម ៤០ % បើប្រៀបធៀបជាមួយឆ្នាំ១៩៧៩ មូលហេតុការប្រើប្រាស់កាន់តែខ្លាំងធ្វើអោយ ការចាប់ពី ធម្មជាតិក៏កាន់តែខ្លាំង និងការប្រើឧបករណ៍នេសាទក៏កាន់តែមានច្រើនឡើងៗនិង មានលក្ខណៈទំនើបបន្តិចម្តងៗ ។ ចាប់ពីឆ្នាំ ២០០០ រហូតមកដល់ឆ្នាំ ២០០២ (បច្ចុប្បន្ន) ត្រីក្នុងធម្មជាតិបានមានការថយចុះយ៉ាងខ្លាំងបើប្រៀបធៀបទៅឆ្នាំ ១៩៧៩ គឺនៅតែប្រមាណជា ២០% ប៉ុណ្ណោះដោយសារតំរូវការហូបចុករបស់មនុស្សកាន់កើនឡើងជាលំដាប់ពីមួយឆ្នាំទៅមួយឆ្នាំ, ការចាប់ពីធម្មជាតិកាន់តែខ្លាំង, ឧបករណ៍នេសាទកាន់តែទំនើប ជាពិសេសការប្រើប្រាស់ឧបករណ៍នេសាទខុសច្បាប់ដូចជា ការប្រើប្រាស់ឧបករណ៍អាំងវែកទ័រឆក់ត្រីការប្រើប្រាស់ឧបករណ៍អួនស្បៃមុងជាដើម..។ ក្រៅពីនេះមានជនកំលាំងប្រដាប់អាវុធធ្វើជាខ្នងបង្អែកអោយជនល្មើសនេសាទ ដូចនេះ ធ្វើអោយភាពអានាធិបតេយ្យនេសាទមានជាលំដាប់ ប៉ុន្តែដោយមានគោលនយោបាយកែទំរង់វិស័យជលផលរបស់ រាជរដ្ឋាភិបាលមកភាពអានាធិបតេយ្យ នេះបានត្រូវលុបបំបាត់ស្ទើរទាំងស្រុង ។

- តំលៃផលិតផល : ផលិតផលដែលពួកគាត់ផលិតបាន គាត់លក់ក្នុងតំលៃមួយអតិបរមា គឺនៅឆ្នាំ ១៩៨៥-១៩៩៧ ដោយសារតំរូវការប្រើប្រាស់ក្នុងស្រុកមានចំនួនច្រើន, ផលិតផលមានគុណភាពល្អ និង គ្មានការនាំ ចូលផលិតផលដំណាំពីប្រទេសក្រៅ ហើយចាប់ពីឆ្នាំ ១៩៩៧-២000 តំលៃផលិតផលចាប់ ស្រុតចុះយ៉ាងខ្លាំងដល់ ក៏រិតអប្បរិមាបើប្រៀបធៀបទៅនឹងឆ្នាំ ១៩៨៥-១៩៩៧ ដោយសារផលិតផលគ្មានគុណភាព , ការនាំចូលផលិតផល នេះពីប្រទេសក្រៅមានចំនួនច្រើនលក់ក្នុងតំលៃថោកជាងផលដំណាំក្នុងស្រុក, ពុំសូវមានការនិយមប្រើប្រាស់ផលិតផល ក្នុងស្រុក រហូតមកដល់បច្ចុប្បន្ន តំលៃផលិតផលរបស់គាត់ នៅទាបដដែល ។

- សត្វចង្រៃបំផ្លាញដំណាំ : នៅឆ្នាំ ១៩៨៥-១៩៩០ ការបំផ្លាញដំណាំរបស់សត្វចង្រៃមានសភាពធម្មតាពុំមានលក្ខណៈធ្ងន់ធ្ងរ ។ ចាប់ពីឆ្នាំ ១៩៩៧-២00២ ( បច្ចុប្បន្ន ) ការបំផ្លាញដំណាំរបស់សត្វចង្រៃមានការកើន ឡើងយ៉ាងធ្ងន់ធ្ងរធ្វើអោយផលដំណាំហិនហោចទទួលបានផលតិចតួច ។

- ការប្រើប្រាស់ថ្នាំពុល : នៅឆ្នាំ ១៩៨៥-១៩៩០ ការប្រើប្រាស់ថ្នាំពុលមានកំរិតទាបគឺប្រ មាណពី ៥%-១៥% ដោយសារល័ក្ខខ័ណ្ឌធម្មជាតិអំណោយផលល្អទើបពួកគាត់មិនសូវប្រើប្រាស់ថ្នាំពុល ។ ចាប់ពីឆ្នាំ ១៩៩៧-២00២ ( បច្ចុប្បន្ន ) ការប្រើប្រាស់ថ្នាំពុលមានការកើនឡើងយ៉ាងខ្លាំង ដោយសារធម្មជាតិមិនអំណោយផលកើតសត្វចង្រៃបំផ្លាញដំណាំមានចំនួនច្រើន ។

- ទិន្នផលដំណាំ : ចំពោះផលដំណាំដែលអ្នកភូមិប្រកបការដាំដុះនាឆ្នាំ ១៩៨១ -១៩៩៥ ទទួលបាន ផលប្រមាណជា ៦0% ទៅ ៨0 % ។ ចាប់ពីឆ្នាំ១៩៩៧-២000 ទិន្នផលដំណាំគ្រប់ប្រភេទរបស់ ពួកគាត់មានការ ថយចុះយ៉ាងខ្លាំង ដោយសារសត្វចង្រៃបំផ្លាញ,បាត់បង់នូវប្រភេទសត្វមានប្រយោជន៍ដែលស៊ីសត្វចង្រៃជាអាហារ( គីង្គក់, កង្កែប, សត្វស្លាប និងពស់ ) ។ នៅឆ្នាំ២00២ ( បច្ចុប្បន្ន ) ផលដំណាំមានការ កើនឡើងបន្តិចបន្តួច ដោយសារការ ប្រើប្រាស់ថ្នាំពុលដែលមានកំរិតពុលខ្ពស់ ។

- គ្រឿងយន្តកសិកម្ម : នៅឆ្នាំ១៩៨១ ការកាប់ព្រៃ,រានដី,ភ្ជួរដី អ្នកភូមិប្រើដោយកំលាំងមនុស្ស ប៉ុន្តែចាប់ពីឆ្នាំ ១៩៨៩-១៩៩៥ ទើបមានការប្រើប្រាស់គោយន្តចំនួន ២ គ្រឿង និង ចាប់ពីឆ្នាំ ១៩៩៥ មកដល់បច្ចុប្បន្ន មានការកើនឡើងជាបន្តបន្ទាប់រហូតដល់មានចំនួន ៤៨ គ្រឿង ។

- ការបាក់ដីច្រាំងទន្លេ : ការបាក់ដីច្រាំងទន្លេគឺបណ្តាលមកពីកាណូតរ៉ូយ៉ាល់ ។ ការបាក់ដីច្រាំងដែលគួរអោយកត់សំគាល់នោះគឺនៅឆ្នាំ ១៩៨៦ ដែលមានវត្តមានកាណូតរ៉ូយ៉ាល់ ហើយដីច្រាំងនេះចេះតែបន្តបាក់រហូតនិងមានការបាក់ខ្លាំងនៅឆ្នាំ ១៩៩៩ ។ ចាប់ពីឆ្នាំ ១៩៩៩-២00២ ការបាក់ដីច្រាំងមានសន្ទុះកាន់តែខ្លាំងគឺមានប្រវែង ៥ម ( ច្រាំង ទន្លេម្ខាង ) ។

### ២.៣.៣ ភាពរងគ្រោះ

យោងតាមការសិក្សាខាងលើនេះ បានបង្ហាញអោយឃើញនូវភាពរងគ្រោះរបស់អ្នកភូមិដូចជា :

-ប្រជាជនកាន់តែលើនឡើង ផ្ទៃដីកសិកម្មប្រើប្រាស់មិនគ្រប់គ្រាន់ ផ្ទៃដីធ្វើចំការត្រូវយកមកធ្វើជាដីសង់លំនៅដ្ឋានវិញ ។

- ឈ្មួញបន្ទាបតំលៃផលិតផល និង មានអត្រាការប្រាក់ខ្ពស់

- គ្រួសារក្រ និង គ្រួសារទ័លក្រ  កាន់តែមានអត្រាកើនឡើងជាលំដាប់

- សត្វល្អិតបំផ្លាញដំណាំបណ្ដាលអោយទទួលបានផលតិច

- ការប្រើប្រាស់ថ្នាំពុលធ្វើអោយប៉ះពាល់ដល់ផលដំណាំ និង សុខភាពរបស់ប្រជាជន

- កប៉ាល់រ៉ូយ៉ាល់បានបំផ្លាញអោយខូចទ្រព្យសម្បត្តិ និង ជំរកត្រីពងកូន


អត្រានៃការបំផ្លាញរបស់សត្វល្អិត
ភាគរយ
100
80
60
40
20
1985
90
97
99
00
01
02
ឆ្នាំ


ការប្រើប្រាស់ថ្នាំពុល
ភាគរយ
100 %
90 %
50 %
15 %
5 %
1985
90
96
97
98
99
00
02
ឆ្នាំ


ទិន្នផលដំណាំតាមបណ្ដាឆ្នាំនីមួយៗ
ភាគរយ
100
80
60
40
20
1981
85
90
96
97
00
02
ឆ្នាំ


តំលៃកសិផល
ភាគរយ
100
80
60
40
20
1985
90
95
97
98
00
02
ឆ្នាំ




រូបភាពទី៧ : ការប្រែប្រួល

## ២.៤ ស្ថាប័ន និង ដំណើរការ

<u>រដ្ឋាភិបាល</u>

- មេក្រុម
- មេភូមិ
- មណ្ឌលសុខភាពឃុំ
- ក្រុមប្រឹក្សាឃុំ
- សាលារៀន
- សហគមន៍នេសាទ
- កសិកម្ម
- អាជ្ញាធរស្រុក
- គ្រូបង្រៀន

<u>សង្គមស៊ីវិល</u>

- គណៈកម្មការភូមិ
- ចាស់ព្រឹទ្ធាចារ្យ
- ឆ្មបបូរាណ
- ពេទ្យឯកជន
- សាលាបុណ្យ

<u>អ្នកជំនួញ</u>

- ឈ្មួញ (អោយខ្ចីលុយ)
- ឥណទានប្រាសាក់
- ធនាគារស្រូវ

តារាងទី៤:ការវិភាគលើស្ថាប័នពាក់ព័ន្ធក្នុងភូមិកោះបួស្សី

| | | **វិជ្ជមាន** | **អព្យាក្រឹត្យ** | **អវិជ្ជមាន** |
|---|---|---|---|---|
| រដ្ឋាភិបាល | - មេក្រុម | ✓ | | |
| | - មេភូមិ | ✓ | | |
| | - មណ្ឌលសុខភាពឃុំ | ✓ | | |
| | - ក្រុមប្រឹក្សាឃុំ | | ✓ | |
| | - សាលារៀន | ✓ | | |
| | - សហគមន៍នេសាទ | ✓ | | |
| | - កសិកម្ម | | | ✓ |
| | - អាជ្ញាធរស្រុក | | ✓ | |
| | - គ្រូបង្រៀន | ✓ | | |
| អ្នកជំនួញ | - ឈ្មួញ (អោយខ្ចីប្រាក់) | | | ✓ |
| | - ឥណទានប្រាសាក់ | | | ✓ |
| | - អង្គការទស្សនៈពិភពលោកផ្តល់ស្រូវអោយខ្ចី | | | ✓ |

| | | | | |
|---|---|---|---|---|
| សង្គមស៊ីវិល | - គណៈកម្មការភូមិ | ✓ | | |
| | - ចាស់ព្រឹទ្ធាចារ្យ | ✓ | | |
| | - ឆ្មបបុរាណ | ✓ | | |
| | - ពេទ្យឯកជន | | | ✓ |
| | - សាលាបុណ្យ | ✓ | | |

ការធ្វើវ៉ែនដ្យាក្រាមបានបញ្ជាក់អោយឃើញថា : ទំនាក់ទំនងរវាងអ្នកភូមិ ជាមួយនឹងស្ថាប័នផ្សេងៗ អ្នកធ្វើជំនួញ និង សង្គមស៊ីវិលរួមមាន :

- រដ្ឋាភិបាល :

+ មេក្រុមមានតួនាទីសំខាន់ ជាអ្នកពាំនាំនូវផែនការដែលភូមិដាក់ចុះ និង ដោះស្រាយរាល់បញ្ហាកើតមានឡើងក្នុងក្រុម ។

+ មេភូមិ ជាអ្នកគ្រប់គ្រងទទួលខុសត្រូវទាំងស្រុង ដោះស្រាយរាល់បញ្ហាដែលកើតមានឡើង និង ពាំនាំ នូវរាល់សំណូមពររបស់អ្នកភូមិទៅថ្នាក់ឃុំ ចាត់ចែងរាល់ការងារទូទៅពិសេសជាអ្នកទំនាក់ទំនងជាមួយនិងស្ថាប័នខាងក្រៅ ។

+ មណ្ឌលសុខភាពឃុំ មានតួនាទីចុះអប់រំសុខភាពដល់ប្រជាជន និង កុមារក្នុងភូមិ

+ មេឃុំ និង អាជ្ញាធរស្រុក ត្រូវបានអ្នកភូមិចាត់ទុកថា ជាអាជ្ញាធរ ដើរតួយ៉ាងសំខាន់ ក្នុងការធ្វើអន្តរាគមន៏ រាល់បញ្ហាទាំងឡាយដែលភូមិកើតមានឡើង ។

+ សាលារៀនជាថ្នាល បណ្តុះបណ្តាលធនធានមនុស្ស ។

+ សហគមន៏នេសាទ មានទួនាទីសំខាន់ក្នុងការការពារប្រភពធនធានធម្មជាតិ (ពិសេសធនធានជលផល) ដែលមាននៅក្នុងភូមិ ។

+ កសិកម្ម អ្នកភូមិចាត់ទុកថាជាស្ថាប័នមួយយ៉ាងសំខាន់ក្នុងការផ្តល់បច្ចេកវិទ្យាក្នុងការប្រកបមុខរបរកសិកម្ម ប៉ុន្តែស្ថាប័ន នេះពុំដែលមានទំនាក់ទំនងក្នុងភូមិគាត់ឡើយ ។

- អ្នកជំនួញ :

+ ឈ្មួញ មានសារៈសំខាន់ណាស់ចំពោះអ្នកភូមិ ក្នុងការជួយផ្តល់ជាទុន សំភារៈ និង ទិញផលិតផលរបស់ពួកគាត់ប៉ុន្តែឈ្មួញក៏កាប់សង្កត់ដោយយកការប្រាក់ខ្ពស់គិតតែយកចំណេញគ្មានប្រាក់សងរឹបអូសយកទ្រព្យសម្បត្តិ និង បន្ថោកតំលៃកសិផល ។

+ អង្គការប្រាសាក់សំខាន់ដែរ ក្នុងការផ្តល់ទុនអោយខ្ចីមួយដងមួយកាល ពេលខ្ចីត្រូវមានក្រុម និង សំភារៈធានា (ពុំមាននៅក្នុងភូមិនេះទេ អ្នកភូមិទៅខ្ចីនៅស្រុកដែលមានកម្មវិធីប្រាសាក់) ។

+ អង្គការទស្សនៈពិភពលោក ជួយផ្តល់ស្រូវពូជ អោយអ្នកភូមិចំនួន ៨ គ្រួសារ ដោយយកអត្រាការស្រូវ ១៥ % រយៈពេល ៣ខែ ( ទើបនឹងសាកល្បង) ។

- សង្គមស៊ីវិល :

+ គណៈកម្មការភូមិ និង ចាស់ព្រឹទ្ធាចារ្យ មានតួនាទីសំខាន់ណាស់ ក្នុងការអប់រំ ផ្តល់ដំបូន្មាន ។

+ ឆ្មបបូរាណ មានសារៈសំខាន់ណាស់ សំរាប់អ្នកភូមិ ក្នុងការជួយសំរាលកូន ដល់ស្ត្រី និងផ្តល់ដំបូន្មានតាមវិធីបូរាណ ។

+ ពេទ្យឯកជន សំខាន់ដែរ ក្នុងការជួយព្យាបាលជំងឺអោយអ្នកភូមិ ( ដោយគិតថ្លៃព្យាបាល ) ។

## ២.៥ យុទ្ធសាស្ត្រនៃការចិញ្ចឹមជីវិត

តាមការសិក្សាអំពី ការចិញ្ចឹមជីវិតរបស់អ្នកភូមិកោះឫស្សី បានឆ្លុះបញ្ចាំងអោយឃើញនូវយុទ្ធសាស្ត្រ សំខាន់ គឺ :

- ការដាំដំណាំចំការ និង របរនេសាទត្រី ។ ចំពោះអ្នកទ័លក្រ និង អ្នកក្របានឆ្លៀតឱកាសចេញទៅស៊ីឈ្នួល គេ ដូចជា កាប់ព្រៃ , ធ្វើស្មៅ ,កាត់ដេរ ។ ល ។ ក្រៅពីនេះអ្នកភូមិមួយចំនួនបានកែច្នៃផលនេសាទ "ធ្វើប្រហុក ផ្អកឆ្អើរត្រី " និង ដាំដំណាំអនុផល "ធ្វើម្ទេសឆ្អើរហាលថ្នាំជក់ " ។

ចំពោះអ្នកមានជំនាញផ្ទាល់ខ្លួនប្រកបមុខរបរផ្សេងៗទៀត ដូចជា ជួលជុលម៉ាស៊ីនទូកកាណូត បញ្ចូលអាគុយ ដំដែក តម្បាញថែប ។ល។

### ២.៥.១ បញ្ហាជួបប្រទះ និង ការចាត់ថ្នាក់

ទោះបីអ្នកភូមិមានមុខរបរដូចខាងលើនេះក៏ដោយ លទ្ធផលដែលទទួលបានក៏ពុំអាចបំពេញនូវសេចក្តីត្រូវការក្នុងជីវភាពរបស់ពួកគាត់បានដែរ គាត់ជួបប្រទះនូវបញ្ហាជាច្រើនដូចជា : ខ្វះពូជដំណាំ , ឥណទាន , ឧបករណ៍នេសាទ , ម៉ាស៊ីនបូមទឹក,ទូកកាណូត,ដីចំការ,សត្វល្អិតបំផ្លាញ, មណ្ឌលសុខភាព , កូនច្រើន , គ្រូបង្រៀន ,ផលិតផលចុះថោក , ខ្វះបច្ចេកទេសប្រើប្រាស់ថ្នាំពុល, បាក់ច្រាំងទន្លេ, ខ្វះចំណេះដឹង , ខ្វះបច្ចេកទេសដាំដុះដាក់រូបភាព ។

វិធីសាស្ត្រជ្រើសរើសបញ្ហា និង ការវិភាគ

-អ្នកភូមិចូលរួមចំនួន ៤៧ នាក់ ស្រី ២៨ នាក់

-អ្នកភូមិម្នាក់ៗមានគ្រាប់ពោត ១០គ្រាប់ បន្ទាប់មកអ្នកសំរបសំរួលបានកំណត់ថា : បញ្ហាដែលអ្នកភូមិចាត់ទុកថាសំខាន់ ត្រូវដាក់គ្រាប់ពោតចំនួន ៥គ្រាប់ បញ្ហាសំខាន់បន្តបន្ទាប់អ្នកភូមិត្រូវដាក់គ្រាប់ពោតបន្ថយបន្តបន្ទាប់ ។ (រូបភាព វិភាគបញ្ហា)

អ្នកភូមិធ្វើការវិភាគបញ្ហាខាងលើ ដើម្បីរកដំណោះស្រាយ នឹងធ្វើផែនការសកម្មភាពលើបញ្ហាចំបងចាំបាច់សំរាប់ ពួកគាត់មានដូចខាងក្រោម :

+ បញ្ហាឥណទាន

+ បញ្ហាពូជដំណាំ

+ បញ្ហាទូកកាណូត

+ ឧបករណ៍នេសាទ

### ២.៥.២ ការវិភាគលើបញ្ហា

តាមការសិក្សាលើបញ្ហាសំខាន់ទាំងបួនខាងលើឃើញថា បញ្ហាទាំងអស់ទាក់ទងទៅនឹងឥណទានដូច

គ្អា អ្នកភូមិសំរេចយកបញ្ហាសំខាន់ពីរមកវិភាគ :

- បញ្ហាខ្វះឥណទាន :

តាមលទ្ធផលនៃការចាត់ថ្នាក់បញ្ហាដែលធ្វើឡើងតាមការបោះឆ្នោត អ្នកភូមិចាប់អារម្មណ៍សំខាន់ជាងគេ គឺខ្វះឥណទានព្រោះ មុខរបរចិញ្ចឹមជីវិតរបស់ពួកគាត់ ត្រូវផ្អែកទៅលើថវិកាដែលបច្ចុប្បន្នគាត់កំពុងខ្វះខាតស្ទើរទាំងស្រុងក្រៅពីមធ្យោបាយផ្សេងៗដែលមានស្រាប់ ។

ឫសគល់នៃបញ្ហាគឺ ខ្វះឥណទានសំរាប់ធ្វើកសិកម្ម និង ធ្វើនេសាទត្រីបណ្តាលអោយខ្វះដើមទុនព្រោះកន្លងមកអ្នកភូមិជួបប្រទះនូវគ្រោះធម្មជាតិ (សត្វល្អិតបំផ្លាញ, ក្តៅខ្លាំងភ្លៀងខុសរដូវ) គ្មានអង្គការស្ថាប័នមកជួយផ្តល់ទុនឱ្យ ខ្ចីដោយសារភូមិជាតំបន់ផ្លូវទឹកលំបាកក្នុងការទំនាក់ទំនង ។

បើខ្ចីទុនពីឈ្មួញៗត្រូវការសំភារះ ឬ មរតកបញ្ចាំ ព្រោះ (ដីមានតិចតួច)

មែកធាងបញ្ហាផ្តើមចេញពីការខ្វះឥណទានខាងលើនេះបណ្តាលអោយអ្នកភូមិជួបប្រទះការលំបាកធ្វើអោយពួកគាត់ចេញទៅស៊ីឈ្នួលគេដើម្បីរកកំរៃបន្ថែម ខ្វះស្បៀងហូបនៅរដូវវស្សា ខ្វះឧបករណ៍នេសាទ អ្នកភូមិត្រូវបង្ខំចិត្តទៅខ្ចីឈ្មួញខាងក្រៅ ឈ្មួញយកការប្រាក់ខ្ពស់ ផលិតផលដែលអ្នកភូមិធ្វើបានត្រូវលក់អោយម្ចាស់លុយក្នុងកំរៃទាបពេលប្រមូលលុយ បើអ្នកភូមិគ្មានលុយសងអោយគេឈ្មួញត្រូវរឹបអូសសំភារៈ កាត់យកទូកកាណូតរឺ ដីតាមកិច្ចសន្យាដាក់អោយគេ ។

- បញ្ហាខ្វះទូកកាណូត :

ចំណាត់ថ្នាក់ខ្វះទូកកាណូតជាបញ្ហាចំបងទីពីរដែលត្រូវដោះស្រាយបន្ទាន់។ បញ្ហានេះមានឫសគល់បីគឺ

១- ខ្វះឥណទាន ពីព្រោះគ្មានអង្គការអោយខ្ចីប្រាក់

២- ខ្វះដើមទុន មូលហេតុកន្លងមកគ្រោះធម្មជាតិ (សត្វល្អិតបំផ្លាញ, ភ្លៀងខុសរដូវ) ផលទទួលបានតិច, តំលៃផលិតផលទាប, ធនធានធម្មជាតិនៅក្នុងភូមិមានការថយចុះ ។

៣- ខ្វះអ្នកអោយជួលទូកកាណូត អោយ ឬ ខ្ចី ព្រោះគេត្រូវការប្រើប្រាស់សំរាប់បំរើការងារផ្ទាល់ខ្លួនរបស់គេ ។

មែកធាងនៃបញ្ហាខ្វះទូកកាណូតនេះ បណ្តាលអោយមានភាពទំនេរគ្មានការងារធ្វើ ខកខានមិនបានចេញទៅធ្វើការងារ បើទៅដោយសារជាមួយគេជូនបាន ឬ មិនបានទៅ ម៉្យាងទៀតពួកគាត់អាចជួល ឬ ប្រវ៉ាស់បានដោយជួយលើកដាក់លីសែងប្រមូលផលអោយអ្នកមានទូកកាណូត ។

រាល់ឫសគល់ និង មែកធាងបញ្ហាខ្វះទូកកាណូតបានបង្ហាញអោយឃើញដល់ការប៉ះពាល់មួយចំនួនដូចជា ផលដំណាំថយចុះ តំលៃផលិតផលទាប និង ខាតបង់ពេលវេលា ។

**ការវិភាគដើមការងារទូកកាណូត**




រូបភាពទី ៨: ការវិភាគមែកធាងនៃបញ្ហា

### ២.៥.៣ ផែនការសកម្មភាព

ក្រោយពីបានចាត់ថ្នាក់ និងវិភាគបញ្ហាដែលទាក់ទងទៅលើមុខរបរចិញ្ចឹមជីវិតរបស់អ្នកភូមិកោះឫស្សី មានចំនួន ៤ ក្នុងនោះមាន : ខ្វះពូជដំណាំ, ខ្វះទូកកាណូត, ខ្វះឧបករណ៍នេសាទ និង ខ្វះឥណទាន ។ ដោយបញ្ហាទាំងនេះទាក់ទងទៅនឹងជីវិកា អ្នកភូមិបានពិភាក្សាឯកភាពគ្នាលើកយកបញ្ហាឥណទានតែមួយមកធ្វើផែនការសកម្មភាព ។

តារាងទី៥: ផែនការសកម្មភាព

| ជំហ៊ាន | អ្នកផ្តួចផ្តើម | អ្នកចូលរួម | សំភារៈ | បញ្ហា | ពេលវេលា |
|---|---|---|---|---|---|
| **ជំហ៊ាន ១** | | | | | |
| -បង្កើតគណៈកម្មការគ្រប់គ្រង | អ្នកភូមិ | អ្នកភូមិ | ប៊ិច-សៀវភៅ | គ្មានបញ្ហា | ១-៨-២០០២ |
| -ចងក្រងក្រុម | អ្នកភូមិ | សមាជិកក្រុម | បញ្ជី-ប៊ិច-សៀវភៅ | -ម្តងអោយចូល,ម្តងអោយចេញ<br>-រត់ចោលក្រុម<br>-ចង់មានតែក្រុមគ្រួសាររបស់ខ្លួនឯង | ១-៨-២០០២ |
| -បង្កើតច្បាប់ , លក្ខន្តិកៈ ,គណៈកម្មការ | អ្នកភូមិ | អ្នកភូមិ | ប៊ិច-សៀវភៅ | ខ្លាចមិនធានានៅពេលច្បាប់កើតឡើង | ៧-៨-២០០២ |
| -បង្កើតច្បាប់សំរាប់ក្រុម | អ្នកភូមិ | សមាជិកក្រុម | ប៊ិច-សៀវភៅ | គ្មានបញ្ហា | ៧-៨-២០០២ |
| -ទំនាក់ទំនងជាមួយអ្នកផ្តល់ដើមទុន<br>"អង្គការ , ឯកជន " | គណៈកម្មការ | ប្រធានក្រុម | - ឯកសារ<br>- ទូក-កាណូត<br>- សំណើសុំខ្ចីប្រាក់<br>- បញ្ជីឈ្មោះអ្នកភូមិ<br>- កិច្ចសន្យា<br>- ស្នាមមេដៃ | - ខ្វះថវិកាធ្វើដំណើរ<br>- ទៅច្រើនលើក<br>- មានការខឹងពីអ្នកភូមិ | ១៥-៨-២០០២ |
| **ជំហ៊ានទី ២** | | | | | |
| - ទំនាក់ទំនងលើកទី ២ | គណកម្មការ | ប្រធានក្រុម | - ឯកសារ<br>- ទូក-កាណូត | - គ្មានថវិកា<br>- ជួបឬមិនជួប | ២០-៨-២០០២ |
| - ទំនាក់ទំនងលើកទី ៣- ៤ | | | | | ៣០-៨-២០០២ |
| **ជំហ៊ានទី ៣** | | | | | |
| ការទទួលប្រាក់ | គណៈកម្មការ | គណៈកម្មការនិងប្រធានក្រុម | មានលិខិតប្រគល់និងទទួល | ខ្លាចបាត់បង់ | |



រូបភាពទី ៩: ទំរង់និរន្តភាពនៃការចិញ្ចឹមជីវិតរបស់អ្នកភូមិកោះឫស្សី

# ៣. សន្និដ្ឋាន និង អនុសាសន៍

## ៣.១ សន្និដ្ឋាន

ឆ្លងតាមការសិក្សាអំពីការចិញ្ចឹមជីវិតរបស់អ្នកភូមិកោះឬស្សី បានបង្ហាញអោយឃើញអំពីស្ថានភាពរស់នៅ ផលប៉ះពាល់ និង រាល់បញ្ហាដែលកើតមានដូចខាងក្រោម :

-ការគ្រប់គ្រងធម្មជាតិអោយមាននិរន្តរភាព ពិសេសត្រី អាចជួយផ្តល់ផលប្រយោជន៍ សំខាន់ដល់អ្នក ទ័លក្រនៅក្នុងភូមិ ។

-ភូមិនេះសំបូរដោយធនធានធម្មជាតិ ប៉ុន្តែសមត្ថភាពមនុស្សក្នុងការទាញយកផលពីធម្មជាតិនៅមាន កំរិត ។

-គណៈកម្មការសហគមន៍នេសាទ ដែលបានបង្កើតឡើង ពុំទាន់មានសមត្ថភាពក្នុងការគ្រប់គ្រងធន ធានធម្មជាតិរបស់ខ្លួន ។ ហើយអ្នកភូមិមួយចំនួនធំពុំទាន់យល់ពីអត្ថប្រយោជន៍នៃការបង្កើតសហគមន៍ នេសាទនៅឡើង។

-កិច្ចខិតខំប្រឹងប្រែងរបស់អ្នកភូមិ ស្ថិតនៅក្រោមឥទ្ធិពលនៃទីផ្សារ និង ធម្មជាតិ កត្តាទាំងនេះហើយ ដែលជាមូលហាតុបណ្តាលអោយពួកគាត់ក្រីក្រ ។

-ការប្រើប្រាស់ថ្នាំពុល និង ជីគីមីរបស់អ្នកភូមិប្រើទៅតាមទំលាប់ត១គ្នាពុំបានអនុវត្តទៅតាមបច្ចេកទេសជាហេតុធ្វើអោយ ប៉ះពាល់ដល់ផលដំណាំ និង សុខភាពពួកគាត់ ។

-ដីភូមិ ដីចំការ និងជំរកត្រី ពងកូនដែលនៅតាមដងទន្លេ បាត់បង់បន្តិចម្តង១ ដោយសាររលកនៃ កប៉ាល់រ៉ូយ៉ាល់ ។

-កំនើនប្រជាជនទល់ក្រមានការកើនឡើងជាលំដាប់ ។

## ៣.២ អនុសាសន៍

យោងតាមផែនការសកម្មភាពលើបញ្ហាឥណទានរបស់អ្នកភូមិដែលបានលើកឡើង សុំអោយមានអន្តរាគមន៍ពីខាងក្រៅទើបមានប្រសិទ្ធភាពក្នុងការប្រកបមុខរបររបស់គាត់ ។

-ស្ថាប័ន និង អង្គការនានាដែលពាក់ព័ន្ធមេត្តាជួយធ្វើអន្តរាគមន៍ចំពោះកប៉ាល់រ៉ូយាល់ត្រូវបន្ថយល្បឿន ក្នុងការធ្វើដំណើរទៅមកកន្លែងដែលមានភូមិប្រជាជនរស់នៅតាមដងទន្លេ ។

-សូមស្ថាប័ន និង អង្គការនានាជួយអន្តរាគមន៍ភ្នាក់ងារចុះជួយផ្សព្វផ្សាយអំពីបច្ចេកទេសប្រើប្រាស់ថ្នាំសំលាប់សត្វល្អិត-ជីគីមី និង បច្ចេកទេសដាំដុះ ។

-ស្ថាប័ន រាជរដ្ឋាភិបាល គួរយកចិត្តទុកដាក់លើធនធានមនុស្សដើម្បីអភិវឌ្ឍន៍ភូមិ ។

-ស្ថាប័ន ជលផល គួរបង្កើត លក្ខន្តិកៈ សហគមន៍នេសាទដោយមានការចូលរួមពីប្រជាជនអោយបាន ឆាប់រហ័សដើម្បីធានានូវការគ្រប់គ្រងនិងប្រើប្រាស់ធនធានធម្មជាតិអោយមាន និរន្តរភាព ។